សមាគមអាដហុក

ADHOC


**សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា**

Cambodian Human Rights and Development Association


# របាយការណ៍

# ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០២២

# មាតិកា

**សេចក្តីផ្តើម** ............ 1
**លទ្ធផលសម្រេចបាន** ............ 4
**ផ្នែកទី១៖ ផ្នែកសិទ្ធិមនុស្ស** ............ 5
១.១. លំហសេរីភាពមូលដ្ឋាន ............ 6
១.២. លំហសេរីភាពនយោបាយ ............ 19
១.៣. ភាពមិនប្រក្រតីនៅពីក្រោយការផ្តិតស្នាមមេដៃលើញត្តិគាំទ្រ ............ 23
១.៤. ករណីទារុណកម្ម និងនិទណ្ឌភាព ............ 24
១.៥. បណ្តឹងបរិហារ ............ 28
**អនុសាសន៍ផ្នែកសិទ្ធិមនុស្ស** ............ 31
**ផ្នែកទី២៖ ផ្នែកសិទ្ធិដីធ្លី** ............ 34
២.១. រំលោភដោយបុគ្គលមានអំណាច ............ 35
២.២. រំលោភដោយអ្នកមានទ្រព្យ ............ 36
២.៣. ការបណ្តេញចេញ ............ 37
២.៤. សម្បទានដីសេដ្ឋកិច្ច ............ 38
**អនុសាសន៍ផ្នែកសិទ្ធិដីធ្លី** ............ 39
**ផ្នែកទី៣៖ ផ្នែកសិទ្ធិស្ត្រី និងកុមារ** ............ 40
៣.១. ករណីជួញដូរផ្លូវភេទ ............ 41
៣.២. ករណីជួញដូរកម្លាំងពលកម្ម ............ 42
៣.៣. ករណីហិង្សាក្នុងគ្រួសារ ............ 43
៣.៤. ករណីរំលោភសេពសន្ថវៈ ............ 45
**អនុសាសន៍ផ្នែកសិទ្ធិស្ត្រី និងកុមារ** ............ 47

# សេចក្ដីផ្ដើម

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា "សមាគមអាដហុក" ជាអង្គការក្រៅរដ្ឋាភិបាលមួយឯករាជ្យ អព្យាក្រឹត មិនរកផលចំណេញ និងមិនស្ថិតក្រោមការឃុំគ្រងរបស់គណបក្សនយោបាយណាមួយឡើយ។ សមាគមអាដហុកជាអង្គការសិទ្ធិមនុស្សដំបូងគេដែលត្រូវបានបង្កើតឡើង នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩១ នឹងត្រូវបានទទួលស្គាល់ជាផ្លូវការដោយសម្ដេចព្រះ នរោត្តម សីហនុ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ ព្រមទាំងចុះបញ្ជីក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ ប្រកាសលេខ២៧៨។

សមាគមអាដហុកមានគោលបំណងប្រមូលផ្ដុំអ្នកស្នេហាសិទ្ធិមនុស្ស និងប្រជាពលរដ្ឋទាំងអស់ ដោយមិនរើសអើងប្រកាន់ដល់ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិឯទៀត ដើមកំណើតជាតិ ឬសង្គម ធនធាន ពូជអំបូរ ឬស្ថានភាពអ្វីណាមួយរបស់គេម្នាក់ៗឡើយ ដើម្បីៈ

- រួមកម្លាំងគ្នារារាំងការសម្លាប់ និងការធ្វើទារុណកម្មលើមនុស្សតាមគ្រប់រូបភាព ដោយយកសេចក្ដីថ្លែងការណ៍ជាសកលនាឆ្នាំ១៩៤៨ ព្រមទាំង អនុសញ្ញា កតិកាសញ្ញានានា ស្ដីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលភាគីខ្មែរទាំងបួនបានចុះហត្ថលេខានាទីក្រុងប៉ារីស និងកំណត់យកគោលការណ៍" អហិង្សា" ជាមូលដ្ឋានក្នុងការការពារ និងធ្វើការដោះស្រាយ ដើម្បីឲ្យមានការគោរពសិទ្ធិមនុស្ស។
- ចូលរួមធ្វើសកម្មភាពយ៉ាងណាឲ្យមានការគោរពសិទ្ធិមនុស្ស បានក្លាយទៅជាការអនុវត្តជាក់ស្ដែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ធ្វើការពង្រឹងនិងពង្រីកនូវចំណេះដឹងសិទ្ធិមនុស្ស ដល់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង ដែលជាកត្តាមួយចាំបាច់បំផុតដល់ការបង្កើនសកម្មភាពឲ្យពលរដ្ឋកាន់តែយល់ដឹងអំពីសិទ្ធិមនុស្សលទ្ធិប្រជាធិបតេយ្យ និងសេរីភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បច្ចុប្បន្នសមាគមអាដហុក ធ្វើសកម្មភាពមានពីរផ្នែកធំៗគឺ ផ្នែកសិទ្ធិមនុស្ស ដីធ្លី និង ធនធានធម្មជាតិ និងផ្នែកសិទ្ធិស្ត្រី និងកុមារ ដែលបាននឹងកំពុងធ្វើប្រតិបត្តិការសកម្មភាពសំខាន់ៗបីដូចជាៈ សកម្មភាពឃ្លាំមើល និងអន្តរាគមន៍ ជួយដល់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស សកម្មភាពពង្រឹងសិទ្ធិអំណាច និងសកម្មភាពការតស៊ូមតិ។




សមាគមអាដហុក ធ្វើសកម្មភាពមានវិសាលភាពទូទាំងប្រទេស ដែលមានស្នាក់ការកណ្ដាល នៅរាជធានីភ្នំពេញ ព្រមទាំងមានស្នាក់ការសាខានៅតាមបណ្ដាខេត្តគោលដៅចំនួន១៧ មាន ៖ ១-ខេត្តព្រៃវែង ២-ខេត្តកំពង់ចាម ៣-ខេត្តក្រចេះ ៤-ខេត្តស្ទឹងត្រែង ៥-ខេត្តរតនគីរី ៦-ខេត្តមណ្ឌលគីរី ៧-ខេត្តកំពត ៨-ខេត្តកោះកុង ៩-ខេត្តព្រះសីហនុ ១០-ខេត្តកំពង់ធំ ១១-ខេត្តកំពង់ឆ្នាំង ១២-ខេត្តបាត់ដំបង ១៣-ខេត្តបន្ទាយមានជ័យ ១៤-ខេត្តឧត្តរមានជ័យ ១៥-ខេត្តសៀមរាប ១៦-ខេត្តព្រះវិហារ និង១៧-ខេត្តកំពង់ស្ពឺ។

រយៈពេល៣២ឆ្នាំកន្លងមកនេះ សមាគមអាដហុក បានធ្វើការងារ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋាន សិទ្ធិសេរីភាពនៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្ដល់ជូនប្រជាពលរដ្ឋនូវចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិមនុស្ស ច្បាប់ លទ្ធិប្រជាធិបតេយ្យ របៀបការពារសិទ្ធិ និងសេរីភាពរបស់ខ្លួន។ គោលបំណង

ចម្បងរបស់សមាគមអាដហុក គឺជួយជនរងគ្រោះពីការរំលោភបំពាន ឱ្យចេះស្វែងរកយុត្តិធម៌ ដោយខ្លួនឯង ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋ ជម្មតានៅក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យបញ្ចុះបញ្ចូល ដើម្បីធ្វើការតស៊ូមតិលើកកម្ពស់ និងការកែលម្អច្បាប់ ស្ថាប័ននានា និងការអនុវត្តច្បាប់។

# សមាគមអាដហុក

## ចក្ខុវិស័យ

សង្គមមួយដែលគោរពសិទ្ធិមនុស្ស និងច្បាប់។

## បេសកកម្ម

អប់រំ និងពង្រឹងសិទ្ធិអំណាចជូនប្រជាពលរដ្ឋកម្ពុជា ដើម្បីឱ្យពួកគាត់បានយល់ដឹង និងចេះការពារសិទ្ធិរបស់ខ្លួនដោយខ្លួនឯង និងដើម្បីធ្វើការតស៊ូមតិ និងផ្ដល់ការគាំទ្រដល់អ្នកកាន់អំណាចរដ្ឋ ឱ្យមានការកែប្រែឥរិយាបថឆ្ពោះទៅរកអភិបាលកិច្ចល្អ និងការគោរពសិទ្ធិមនុស្ស។

## គោលដៅ

ជំរុញឱ្យមានការផ្លាស់ប្តូរខាងគោលនយោបាយ និងការអនុវត្តជាក់ស្តែងរបស់ស្ថាប័នលទ្ធិប្រជាធិបតេយ្យ ជាពិសេស ប្រព័ន្ធតុលាការ និងធ្វើការពង្រឹងវិស័យសង្គមស៊ីវិល។

## គុណតម្លៃ

សមាគមអាដហុក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនប្រកាន់គណបក្សនយោបាយ និងមិនរកប្រាក់ចំណេញ។

# លទ្ធផលសម្រេចបាន

**អ្នកទទួលផលសរុប ១០៧,៨៩៨នាក់**




ក្នុងមួយឆ្នាំ២០២២កន្លងមកនេះ សមាគមអាដហុក ធ្វើសកម្មភាព អង្កេត និងអន្តរាគមន៍បាន ៩២១ករណី រួមមាន៖ផ្នែកសិទ្ធិមនុស្សមានចំនួន ៥៩៤ករណី ផ្នែកសិទ្ធិដីធ្លីមានចំនួន៨៤ករណីនិងផ្នែកស្ត្រី និងកុមារមានចំនួន ២៨៨ករណី ដែលជាប្រយោជន៍ដល់ អ្នកទទួលផលសរុបចំនួន ១០៧,៨៩៨នាក់ ក្នុងនោះរួមមាន ផ្នែកសិទ្ធិមនុស្សចំនួន៤៦,៨១០នាក់(ស្ត្រី៣៣,៨៤៥ នាក់) ផ្នែកសិទ្ធិដីធ្លីចំនួន៣៦,៧៦៦នាក់ (ស្ត្រី១៣,០១៥នាក់) និងផ្នែកស្ត្រី និងកុមារ ចំនួន ២៤,៣២២នាក់ ។

**លទ្ធផលសម្រេចបានប្រចាំឆ្នាំ ៨៤.៨៨%**

លទ្ធផលឆ្នាំ២០២២ សម្រេចបាន ៨៤.៨៨% បើធៀបនឹង ផែនការប្រចាំឆ្នាំ ហើយនៅក្នុងនោះ ផ្នែកសិទ្ធិមនុស្សសំរេចបាន១០៤.៥% ផ្នែកសិទ្ធិដីធ្លី សំរេច ៨៦.៣២% ផ្នែកសិទ្ធិស្ត្រី និងកុមារ សម្រេចបាន ៧៥% និងផ្នែកប្រតិបត្តិការ សំរេចបាន៨៦.៥៣%។



# ផ្នែកទី១៖ ផ្នែកសិទ្ធិមនុស្ស




ករណីរំលោភសិទ្ធិមនុស្ស កាន់តែមានសភាពធ្ងន់ធ្ងរឡើងដូចជា នៅក្នុងឆ្នាំ២០២២នេះ ផ្នែកសិទ្ធិមនុស្សនៃសមាគមអាដហុក ធ្វើសកម្មភាពសម្រេចបានលទ្ធផល ១០៤.៥% ធៀបនឹងផែនការប្រចាំឆ្នាំ។ តាមការអង្កេតបានបង្ហាញឲ្យឃើញថា ករណីរំលោភសិទ្ធិមនុស្ស មានចំនួនសរុប៥៤៩ករណី កើនឡើង៣៩២ករណីបើធៀបលទ្ធផលឆ្នាំ២០២១ មានត្រឹមតែ១៥៧ករណីប៉ុណ្ណោះ ក្នុងនោះករណីគំរាមកំហែងសកម្មភាពនយោបាយកើនឡើងរហូតដល់២១៨ករណី ការរឹតត្បឹតសេរីភាពជួបជុំចំនួន១១៨ករណី និងរឹតត្បឹតសេរីភាពបាតុកម្មចំនួន ៦៥ករណី។ ឆ្លងតាមការវិភាគបង្ហាញថា ជាង៥០% នៃករណីគម្រាមកំហែងសកម្មជនសិទ្ធិមនុស្ស សកម្មជននយោបាយ និងករណីរឹតត្បឹតសេរីភាពមូលដ្ឋាន នៅតែមិនត្រូវបានដោះស្រាយ។ ហើយភាគច្រើនបំផុតនៃជនរងគ្រោះ ករណីទាំងនោះ សំរេចមិនដាក់ពាក្យបណ្តឹង ពីព្រោះពួកគាត់មិនមានទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌។

## ១.១. លំហសេរីភាពមូលដ្ឋាន

សេរីភាពមូលដ្ឋាន ជាកត្តាដ៏សំខាន់ នៅក្នុងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ រួមមានសេរីភាពខាងបញ្ចេញមតិសេរីភាពខាងសមាគម និងសេរីភាពខាងជួបជុំ។ ជាពិសេស សេចក្តីពន្យល់ទូទៅសេរីភាពនៃគំនិត និងការសម្តែងមតិអង្គការសហប្រជាជាតិឆ្នាំ២០១១៖ “សេរីភាពបញ្ចេញមតិ គឺជាលក្ខខណ្ឌ ដែលមិនអាចកាត់ផ្តាច់បានសំរាប់ការអភិវឌ្ឍន៍ពេញលេញរបស់មនុស្ស និងមានសារៈសំខាន់ជាសារវន្ត សំរាប់សង្គមជាតិ ដែលបង្កើតជាមូលដ្ឋានគ្រឹះដល់គ្រប់សង្គមប្រជាធិបតេយ្យដោយសេរីភាពបញ្ចេញមតិ ជាយានសំរាប់ការផ្លាស់ប្តូរ និងការ




អភិវឌ្ឍន៍នៃគំនិត។ លើសពីនេះទៀត សេរីភាពបញ្ចេញមតិ គឺជាលក្ខណ្ឌចាំបាច់មួយសំរាប់ការធ្វើឲ្យបាននូវគោលការណ៍នៃតម្លាភាពនិងគណនេយ្យភាពដែលសារៈសំខាន់ ដល់ការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស”

នៅឆ្នាំ២០២២ សមាគមអាដហុក បានសង្កេតឃើញថា មានករណីរឹតត្បិត ការបង្ក្រាបលើសិទ្ធិខាងសេរីភាពបញ្ចេញមតិ និងសេរីភាពជួបជុំ កើនឡើងគួរឲ្យកត់សំគាល់ដូចជា៖ សេរីភាពបញ្ចេញមតិ ៤២ករណី និងសេរីភាពជួបជុំ ១៧៧ករណី ក្នុងនោះមាន ១០២ករណី កើតឡើងនៅរាជធានីភ្នំពេញ ជាពិសេសវិវាទការងាររួម នៅក្រុមហ៊ុនណាហ្គាវើលដ៍។

សមាគមអាដហុកបានដាក់របាយការណ៍របកគំហើញបញ្ហាប្រឈម និងអនុសាសន៍របស់សហគមន៍ទាំង៣៥ នៅក្នុងខេត្តគោលដៅទាំងប្រាំបីទៅក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងគណកម្មាធិការសិទ្ធិមនុស្សជាតិ ដើម្បីស្នើសុំអន្តរាគមន៍ លើបញ្ហាមួយចំនួនពាក់ព័ន្ធសេរីភាពមូលដ្ឋានដូចជា អាជ្ញាធរនៅតែបន្តការឃ្លាំមើល សួរនាំសហគមន៍ចូលរួមសកម្មភាពសង្គម អាជ្ញាធរមិនរក្សាការសម្ងាត់ ចំពោះការរាយការណ៍របស់សហគមន៍អំពីបទល្មើសផ្សេងៗ ការបញ្ចេញមតិពាក់ព័ន្ធបញ្ហានយោបាយត្រូវរឹតត្បិត-បំភិតបំភ័យ ក្រុមប្រឹក្សាឃុំសង្កាត់មិនផ្តល់ កិច្ចសហការក្នុងការអនុញ្ញាតសហគមន៍ បានចូលរួមប្រចាំខែ និងសហគមន៍មានការភ័យខ្លាចក្នុងការបញ្ចេញមតិ ករណីនយោបាយ តាមប្រព័ន្ធបណ្តាញសង្គម...ជាដើម[1]។

## ករណីសិក្សា

## វិវាទការខារបុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍

ពាក្យ "**ណាហ្គា**" បើតាមជំនឿសាសនា គឺតំណាងឲ្យស្តេចនាគ(នាគរាជមានក្បាល៧) ដែលគេជឿថាស្នាក់អាស្រ័យក្នុងទន្លេ។

ក្រុមហ៊ុនណាហ្គាវើលដ៍ មានម្ចាស់ភាគហ៊ុនជាជនជាតិម៉ាឡេស៊ី ទទួលអាជ្ញាប័ណ្ណប្រតិបត្តិការផ្តាច់មុខក្នុងរាជធានីភ្នំពេញ ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាកប៉ាល់មួយស្ថិតនៅលើទន្លេមេគង្គ មិនឆ្ងាយពីព្រះបរមរាជវាំង។ រហូតមកដល់បច្ចុប្បន្ននេះ ក្រុមហ៊ុនណាហ្គាវើលដ៍ បានសាងសង់អាគារធំ ខ្ពស់ៗ ចំនួនពីរជិតគ្នា(ណាហ្គា១ និងណាហ្គា២) នៅលើផ្ទៃដីមិនឆ្ងាយពីដងទន្លេមេគង្គ ស្ថិតនៅជិតរដ្ឋសភាជាតិ និងគណៈកម្មាធិការរៀបចំការបោះឆ្នោតជាតិ ដែលអាគារនិមួយៗ ក្រៅពីកន្លែងលេងល្បែង នៅមានបន្ទប់សំរាប់ភ្ញៀវស្នាក់នៅរាប់ពាន់បន្ទប់ មានភោជនីយដ្ឋានជិត២០កន្លែង មានកន្លែងហាត់ប្រាណ កន្លែងហែលទឹក និង

---

[1] របាយការណ៍បញ្ហាប្រឈម និងអនុសាសន៍ របស់សហគមន៍មូលដ្ឋាន https://www.adhoccambodia.org/km/khmer-%E1%9E%9A%E1%9E%94%E1%9E%B6%E1%9E%99%E2%80%8B%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%8E%E1%9F%8D%E1%9E%9F%E1%9F%81%E1%9E%9A%E1%9E%B8%E1%9E%97%E1%9E%B6%E1%9E%96%E2%80%8B%E1%9E%98%E1%9E%BC%E1%9E%9B/

មានក្លឹបកម្សាន្ត។ មកដល់ត្រឹមឆ្នាំ២០២១ ក្រុមហ៊ុនណាហ្គាវើលដ៍ មានបុគ្គលិកសរុបប្រមាណជា ៨០០០ នាក់កំពុងបំរើការងារ។

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុនណាហ្គាវើលដ៍ បានប្រកាសកាត់បន្ថយបុគ្គលិកដោយសារតែបញ្ហាវិបត្តិកូវីដ១៩ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់អាជីវកម្ម (បើពិនិត្យតាមរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយមួយបានឲ្យដឹងថា ក្រុមហ៊ុនណាហ្គាវើលដ៍បានចំណេញប្រាក់ ១០២លានដុល្លារក្នុងឆ្នាំ២០២០[2] ធ្លាក់ចុះពី ៥២១លានធៀបនឹងឆ្នាំ២០១៩) និងបានចំណេញប្រាក់ ១០៧.៣លានដុល្លារក្នុងឆ្នាំ២០២២[3]។

ក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍ បានចេញសេចក្តីថ្លែងការណ៍ជាលើកដំបូង របស់ខ្លួនដោយរៀបរាប់អំពីហេតុផលសំខាន់ៗ ឈានដល់ការបង្ខំចិត្តបញ្ឈប់បុគ្គលិកគឺដោយសារតែបញ្ហាកូវីដ១៩ ខណៈក្រុមហ៊ុនបានខាតបង់ប្រាក់ចំណូលធ្លាក់ចុះជាង៧៧លានដុល្លារ ក្នុងរយៈ៦ខែឆ្នាំ២០២១។ នៅក្នុងខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុនណាហ្គាវើលដ៍ បានបន្តផែនការកាត់បន្ថយបុគ្គលិក ហើយបញ្ឈប់បុគ្គលិកចំនួន ១៣២៩នាក់ ដែលក្នុងនោះមានមេដឹកនាំ និងសមាជិកសហជិពប្រហែល ៦០០នាក់។ ដោយមិនមានការឯកភាពគ្នា ហើយគណៈគ្រប់គ្រងក្រុមហ៊ុនបដិសេធ ជួបចរចារជាមួយតំណាងសហជិពតែយល់ព្រមជួបចរចាផ្ទាល់ ជាមួយជាមួយបុគ្គលិកម្តងមួយៗវិញ ដូច្នេះហើយបុគ្គលិកដែលត្រូវក្រុមហ៊ុនបញ្ឈប់ បានផ្តិតមេដៃដាក់ពាក្យបណ្តឹងទៅក្រសួងការងារ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនាយកដ្ឋានវិវាទការងារបានផ្សះផ្សាចំនួន២លើក លើការទាមទារ៥ចំណុច មានលទ្ធផលសះជា១ចំណុច និងមិនសះជា៤ចំណុចបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយបន្ត នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១។ ក្រុមប្រឹក្សា អាជ្ញាកណ្តាលបានបើកសវនាការ២លើក ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ចេញសេចក្តីបង្គាប់ទាក់ទងចំណុចមិនសះជាទាំង៤ និងបណ្តឹងទាស់ភាគីនយោជិតទៅនឹងសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលដែលស្នើសុំ៩ចំណុចដោយគ្មានឯកភាពយល់ព្រមពីភាគីវិវាទ ចំពោះដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឈានដល់ដំណាក់កាលចុងក្រោយ បុគ្គលិកទាំងនោះ បានសម្រេចជ្រើសរើសយក ការធ្វើកូដកម្ម ដោយសន្តិវិធីដោយ

[2] https://khmer.cambojanews.com/nagaworld-cuts-out-union-to-lay-off-workers-one-by-one/ and https://cambonomist.com/news/nagacorp-profit-200m-in-2020/
[3] https://www.rfa.org/khmer/news/social-economy/cambodia-nagacorp-returns-to-profit-02092023224625.html

បានធ្វើសេចក្តីជូនដំណឹង ទៅសាលារាជធានីភ្នំពេញ ក្នុងគោលបំណងទាមទារឲ្យក្រុមហ៊ុនបំពេញនូវចំនួនលក្ខខណ្ឌ៩ចំណុច[4]។




(រូបភាព ក្រុមកូដករណាហ្គាវើលដ៍ធ្វើកូដកម្ម នៅចន្លោះស្ថានទូតអូស្ត្រាលី និងស្ថានទូតរុស្ស៊ី)

កូដកម្មដំបូងបានចាប់ផ្តើមពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ មានអ្នកចូលរួមជាងមួយពាន់នាក់ នៅពីមុខក្រុមហ៊ុនណាហ្គាវើលដ៍ ហើយបន្ទាប់ពីកូដកម្មធ្វើឡើងបានចំនួន១៤ថ្ងៃ នៅវេលាម៉ោងប្រមាណជាង៨យប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ កងកម្លាំងសមត្ថកិច្ចបានចាប់ខ្លួនកូដករចំនួន ០៩នាក់ បញ្ជូនទៅស្នងការដ្ឋានរាជ

ធានីភ្នំពេញ ដែល០២ថ្ងៃក្រោយមកសមត្ថកិច្ចបានបញ្ជូនកូដករ ០៦នាក់ ទៅតុលាការ តែ០៣នាក់ផ្សេងទៀតធ្វើការអប់រំ ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព និងអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ។ កូដករទាំង ០៦នាក់ត្រូវបានចោទពីបទ ញុះញង់បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមាត្រា៤៩៤ និងមាត្រា៤៩៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជានិងសំរេចឃុំខ្លួនបណ្ដោះអាសន្ន នៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២។

ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ទោះបីជាកូដករ ០៦នាក់ ត្រូវបានចោទប្រកាន់ និងឃុំខ្លួនបណ្ដោះអាសន្ន ក៏កូដកម្មនៅតែបន្ត ដោយប្រឈមជាមួយកម្លាំងសមត្ថកិច្ច ក្នុងសម្លៀកសំពាក់ឯកសណ្ឋានរាប់រយនាក់ ឈរវាំងមិនអនុញ្ញាតឲ្យធ្វើកូដកម្មនៅមុខក្រុមហ៊ុន ដោយទប់ស្កាត់ក្រុមកូដករឲ្យប្រមូលផ្ដុំគ្នាធ្វើកូដកម្មនៅជិតរបងរដ្ឋសភាជាតិ លើជងផ្លូវចន្លោះទូតអូស្ត្រាលី និងទូតរុស្សី។


រូបថត: ក្រុមកូដកនៅក្នុងរថយន្តពេលបញ្ជូនទៅស្នងការរាជធានីភ្នំពេញ(៣-០១-២០២២)

នាម៉ោងប្រហែល ២:១៥នាទីរសៀល នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ នៅខាងមុខណាហ្គាវើលដ៍ទី២ កម្លាំងសមត្ថកិច្ចបានចាប់កូដករ ១៥នាក់ ក្នុងនោះមានប្រុសម្នាក់ និងស្ត្រីមានផ្ទៃពោះម្នាក់ ដាក់បញ្ចូលក្នុងរថយន្តបញ្ជូនទៅស្នងការរាជធានីភ្នំពេញ ។ ជាងប្រាំមួយម៉ោងក្រោយមក (អំឡុងម៉ោង៨:៣០នាទីយប់ ថ្ងៃទី០៤ ខែមករា) កូដករទាំង១៥នាក់នោះត្រូវបានដោះលែងឲ្យត្រឡប់មកផ្ទះវិញ។

នៅរសៀល ថ្ងៃទី០៤ ខែមករា ម៉ោងជាង៣រសៀល នៅមុខអាគាររដ្ឋសភាជាតិ កម្លាំងសមត្ថកិច្ចបានព័ទ្ធចាប់ថ្នាក់ដឹកនាំសហជិពក្រុមហ៊ុនណាហ្គាវើលដ៍ចំនួន០៣ទៀតដោយក្នុងនោះមានប្រធានសហជិពម្នាក់ ដែលទើបនឹងដើរចេញពីក្នុងរថយន្ត។ ក្រោយពីសាកសួរព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការចោទប្រកាន់០២


រូបថត: ការព័ទ្ធចាប់កញ្ញាឈឹមស៊ីថរ ពេលចុះពីរថយន្ត (៤-០១-២០២២)

នាក់គឺប្រធានសហជិព និងសមាជិកពីបទ ញុះ ញង់ តាមមាត្រា៤៩៤ និងមាត្រា៤៩៥ និងបញ្ជូនឃុំខ្លួនបណ្ដោះអាសន្ន នៅមណ្ឌលអប់រំកែប្រែទី២ ហើយសមាជិកសហជិពម្នាក់ទៀត ត្រូវបានអនុញ្ញាតឲ្យត្រឡប់មកផ្ទះ ដោយដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

ដើម្បីទាមទារដោះលែងតំណាង សហជិពទាំង០៨នាក់ មកចូលរួមដោះស្រាយវិវាទការងារមួយនេះ



រូបថត: ក្រសួងការងារអានសេចក្ដីណែនាំ (៧-០១-២០២២)

កូដករ នៅតែបន្តធ្វើកូដកម្មដោយសន្តិវិធី ចាប់ពីថ្ងៃទី៧ ខែមករា ដោយមានលើកបដារូបថតតំណាងសហជិពទាំង ០៨នាក់អង្គុយសមាធិ បើទោះបីជាកម្លាំងនៃការចូលរួមមានចំនួនថមថយមកត្រឹមជាង៧០០នាក់ និងមានការរំខានពីបុគ្គលិកក្រសួងការងារប្រើរថយន្តពីរគ្រឿង និងឧបករណ៍បំពងសំឡេង ពីរគ្រឿងផ្សព្វផ្សាយអំពីសេចក្ដីណែនាំទល់មុខក្រុមកូដករ មានការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ ព្រមទាំងមានបញ្ហាបន្ទប់ទឹក បង្គន់អនាម័យនៅជិតបរិវេណកន្លែងកូដកម្មខូចទាំងអស់មិនអនុញ្ញាតឲ្យកូដករចូលប្រើប្រាស់។

កូដកម្ម  បានបន្តរហូតដល់ថ្ងៃទី០៤ ខែកុម្ភៈ (កូដកម្មបានចំនួន៤៧ថ្ងៃ)  ក្រសួងសុខាភិបាលចេញសេចក្តីប្រកាសឲ្យកូដករទៅធ្វើតេស្តយកសំណាកកូវីដ-១៩ នៅកោះពេជ្រ។ កូដករ ស្នើឲ្យគ្រូពេទ្យមកធ្វើតេស្តនៅហ្នឹងកន្លែងកូដកម្ម  ដោយមិនមានការឯកភាពគ្នារវាងកូដករ និងក្រុមគ្រូពេទ្យ  ខណៈនោះកម្លាំងសមត្ថកិច្ចបានបិទខ្ទប់ក្រុមកូដករមិនឲ្យចេញចូល ក្នុងបរិវេណកូដកម្មរហូតដល់មានការឯកភាពគ្នា នៅម៉ោងប្រហែល៦និង៤៥នាទីទើបក្រុមកូដករអាចត្រឡប់ទៅផ្ទះវិញបាន។  ទន្ទឹមគ្នានោះដែរ  ប្តីរបស់កូដករម្នាក់(៖) ត្រូវ



បានកម្លាំងសមត្ថកិច្ច ចាប់វាយប្រើហឹង្សាលើផ្ទៃមុខ  និងដងខ្លួន បញ្ជូនទៅប៉ុស្តិ៍រដ្ឋបាល បង្ខំឲ្យលុបរូបភាពដែលគាត់បានថតពេលមានការប៉ះពាក្យសម្តីគ្នារវាងក្រុមកូដករ និងកងកម្លាំងដែលមិនអនុញ្ញាឲ្យត្រឡប់ទៅផ្ទះ។ ជាងមួយម៉ោងក្រោយមក  បន្ទាប់ពីមានការធានាពីប្រពន្ធរបស់គាត់  ទើបកម្លាំងសមត្ថកិច្ចបានដោះលែងឲ្យត្រឡប់ទៅផ្ទះវិញ។

ស្អែកឡើង ថ្ងៃទី០៥ ខែកុម្ភៈ ជាកូដកម្មថ្ងៃទី៤៨  ផ្លូវមួយចំនួន ដែលមានទិសដៅ មកកាន់កន្លែងធ្វើកូដកម្មត្រូវបានបិទ  ហើយនៅចន្លោះមុខទូតរុស្ស៊ី និងអ៊ីអន១ មានរថយន្តជាច្រើនគ្រឿងបានបញ្ឈរងចាំចាប់ដឹកបញ្ជូនកូដករទាំងអស់មកយកសំណាកនៅកោះពេជ្រ។ ការយកសំណាកថ្ងៃដំបូងនេះ បានរកឃើញកូដករ០៤នាក់មានវិជ្ជមានកូវីដ១៩។  នៅម៉ោងប្រហែលជាង៧យប់  កម្លាំងសមត្ថកិច្ច បានចាប់ខ្លួនកូដករចំនួន០៦នាក់បន្ថែមទៀត បញ្ជូនទៅស្នងការដ្ឋានរាជធានីភ្នំពេញ តាមដីការបស់តុលាការពីបទ រារាំងសមត្ថកិច្ច...ក្រោយមកស្ត្រី០៣នាក់ត្រូវបានដោះលែង និងបញ្ជូនខ្លួនកូដករបុរស០៣នាក់ទៅសាកសួរនិងសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារ។  អ្នកជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១(ម១)  និងនៅមណ្ឌលអប់រំកែប្រែទី២(ម២)  គឺសុទ្ធតែជាថ្នាក់ដឹកនាំ  និងសមាជិករបស់សហជិពទ្រទ្រង់សិទ្ធិការងារ  បុគ្គលិកកម្មការខ្មែរនៃក្រុមហ៊ុនណាហ្គាវិលដ៍ (LRSU)។



រូបថត: (២១-កុម្ភៈ-២០២២)

កូដកម្មត្រូវបានផ្អាក ចាប់ថ្ងៃទី០៦រហូតដល់ថ្ងៃទី២០ខែកុម្ភៈ ដោយអនុវត្តន៍ តាមគោលការណ៍ក្រសួងសុខាភិបាល។ ហើយនៅថ្ងៃទី២១ខែកុម្ភៈ កូដកម្មបានចាប់ផ្តើមធ្វើឡើងវិញ បន្ទាប់ពីផ្អាកធ្វើចត្តឡីស័កមួយរយៈមក ប៉ុន្តែខណៈពេលនោះ កម្លាំងសមត្ថកិច្ចបានចាប់កូដករ ៦៤នាក់ដឹកតាមរថយន្តទៅកាន់ សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ព្រៃកញ្ចៅ([illegible])។ ម៉ោងប្រហែល១០យប់ កូដករទាំងអស់ បានអនុញ្ញាតឲ្យត្រឡប់មកផ្ទះលើកលែងតែ ០២នាក់ មានវិជ្ជមានកូវិដ បញ្ជូនទៅព្យាបាលនូវពហុកីឡាស្ថានអូឡាំពិក ក្រោយពីធ្វើតេស្តយកសំណាក។ ក្រោមការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ រាល់សកម្មភាពក្រុមកូដករ នៅថ្ងៃទី២២ សមត្ថកិច្ចបានចាប់កូដករ ៣៩នាក់ ដឹកតាមរថយន្តទៅកាន់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ស្ថិតនៅព្រៃកញ្ចៅ ហើយថែមទាំងបង្ខំកូដករ ទាំងនោះឲ្យបំពេញទម្រង់បែបបទ បើនរណាមិនបំពេញ គឺមិនឲ្យហូបបាយ និងមិនអនុញ្ញាតត្រឡប់ទៅផ្ទះវិញទេ។ ដល់ថ្ងៃទី២៣កម្លាំងសមត្ថកិច្ចបានចាប់កូដករចំនួន៥១នាក់បន្ថែមទៀត បញ្ជូនតាមរថយន្តទៅសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅព្រៃកញ្ចៅ ហើយអ្នកទាំងនោះត្រូវបានឃាត់ឲ្យនៅទីនោះមួយយប់ ទាំងគ្មានសំលៀកបំពាក់ផ្លាស់ប្តូរ និងម្ហូបអាហារមិនគ្រប់គ្រាន់។ ដល់ថ្ងៃទី២៤ កូដករ ២៩នាក់ បន្ថែមទៀត ត្រូវបានចាប់បញ្ជូនតាមរថយន្តទៅសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅព្រៃកញ្ចៅ។ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ការធ្វើកូដកម្មត្រូវបានផ្អាក ដោយជំនួសមកវិញ នូវការធ្វើយុទ្ធនាការតស៊ូមតិតាមបណ្តាញសង្គម។

មកដល់ថ្ងៃទី៧ខែមីនា បន្ទាប់ពីកូដករប្រមូលគ្នាធ្វើកូដកម្មឡើងវិញ នៅពេលនោះកម្លាំងសមត្ថកិច្ចក៏បានចាប់កូដករចំនួន ១៨៣នាក់ មានបុរស ២៨នាក់ បញ្ជូនតាមរថយន្តទៅកាន់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅព្រៃកញ្ចៅ រហូតដល់ថ្ងៃទី៨ ខែមីនា ទើបអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ។

នៅថ្ងៃទី០៩ខែមីនា មានការរៀបចំកិច្ចប្រជុំបិទទ្វារ ដើម្បីរកដំណោះស្រាយវិវាទ ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលារាជធានីភ្នំពេញ

ជាមួយក្រសួងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ។ មិនមានលទ្ធផលណាមួយ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្រៅពីសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ និយាយអំពីវឌ្ឍនភាពនៃវិវាទនេះឡើយ ដែលក្នុងនោះមានបញ្ជាក់ផងដែរថា៖ គិតត្រឹមថ្ងៃទី៩ ខែមីនានេះ មានអតីតបុគ្គលិកចំនួន ១៤៧នាក់ ក្នុងចំណោម ៣៧៣នាក់ បានទទួលយកការទូទាត់សំណងពីក្រុមហ៊ុន ណាហ្គាវើលដ៍។


កម្លាំងសមត្ថកិច្ចបង្ខំរុញកូដករឡើងរថយន្ត(៣០-មិនា-២០២២)

នាព្រឹកថ្ងៃទី១០ ខែមីនា សាលាឧទ្ធរណ៍រាជធានីភ្នំពេញបានប្រកាស បដិសេធ ករណីសុំនៅក្រៅឃុំ របស់ជនជាប់ចោទទាំង០៨រូបជាអតីតថ្នាក់ដឹកនាំនិងសមាជិករបស់សហជិពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវិលដ៍ (LRSU)ប៉ុន្តែនៅម៉ោងប្រហែល៧យប់ថ្ងៃទី១៤ខែមីនាអ្នកទាំង០៨នាក់នោះ ត្រូវបានតុលាការដោះលែងឲ្យនៅក្រៅឃុំ បន្ទាប់ពីពួកគេបានធ្វើលិខិតដាក់ស្នើសុំនៅក្រៅឃុំកាល់ពីថ្ងៃទី១២ ខែមិនា"**<u>រហូតមកដល់ថ្ងៃដោះលែងនេះពួកគេបានជាប់ឃុំបណ្តោះអាសន្នអស់រយៈពេល៧៤ថ្ងៃ</u>**"។

ការប្រមូលផ្តុំគ្នាធ្វើកូដកម្ម នៅតែប្រឈមមុខខ្ពស់ ជាមួយការគំរាមកំហែង ការបង្ក្រាប ពីសំណាក់កម្លាំងមានសមត្ថកិច្ច ដែលបានត្រៀមជាស្រេច ក្នុងការចាប់បង្ខំកូដកររុញបញ្ចូលរថយន្ត(■) បញ្ជូនទៅចេញពីទីក្រុង។ សកម្មភាពបង្ក្រាបនេះ តែងតែអនុវត្តដោយកម្លាំងអាជ្ញាធរ នៅពេលកូដករប្រមូលផ្តុំគ្នាធ្វើកូដកម្ម ហើយអាជ្ញាធរមិនអនុញ្ញាតឲ្យអ្នកឃ្លាំមើលអង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន ចូលជិតព្រមទាំងបង្ខំឲ្យលុបរូបចេញ និងជួនកាលចាប់រុញអ្នកការសែតចូលរថយន្តមានដូចកាលបរិច្ឆេទខាងក្រោម ៖

- **ពីថ្ងៃទី០៧ ដល់ថ្ងៃ១៧ ខែមីនា ឆ្នាំ២០២២៖**ចាប់បញ្ជូនកូដករទាំងបង្ខំដាក់រថយន្តជាង១០០នាក់ រាល់ថ្ងៃយកទៅដាក់នៅ សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍នៅព្រែកព្នៅ។



- **ពីថ្ងៃទី១៨ ដល់ថ្ងៃ២០ ខែមីនា ឆ្នាំ២០២២៖** ចាប់បញ្ជូនកូដករ ជាង១០០នាក់ រាល់ថ្ងៃយក ទៅដាក់ចោលនៅ ទីលានប្រជាធិបតេយ្យ ដោយទុកឲ្យក្រុមកូដករដើរត្រឡប់មកផ្ទះវិញ ដោយខ្លួនឯង។

- **ពីថ្ងៃទី២១ដល់ថ្ងៃខែ៣០មិថុនាឆ្នាំ២០២២៖** ចាប់បង្ខំកូដករឡើង រថយន្តពីកន្លែងធ្វើកូដកម្ម មុំក្រុមហ៊ុនណាហ្គាវើលដ៏ ពេលខ្លះប្រើ ហិង្សារុញច្រាន រហូតដល់មានរបួសរាង្គកាយ ហើយដឹកយកទៅ ដាក់ចោលជាយក្រុងសួនវិមានឈ្នះៗ រហូតដល់ម៉ោងប្រាំមួយ ល្ងាចទើបរថយន្តដឹកត្រឡប់មកដាក់ នៅទីលានប្រជាធិបតេយ្យ ទុកឲ្យក្រុមកូដករដើរត្រឡប់មកផ្ទះវិញដោយខ្លួនឯង។ ដូចជានៅ ថ្ងៃទី០២ខែមិថុនា ឆ្នាំ២០២២[5] កូដករម្នាក់ត្រូវបានកម្លាំងអាជ្ញាធរ រុញច្រានខ្ទប់នឹងបង្កាន់ដៃរថយន្ត រហូតដល់ប៉ះពាល់ដល់ទារកក្នុងផ្ទៃស្លាប់។



កូដកររងរបួស (១១-សីហា-២០២២)

- **នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២៖** កូដករណាហ្គាវើលដ៏ ម្នាក់ត្រូវបានអាជ្ញាធរ និងក្រុមសន្តិសុខ ប្រើអំពើហឹង្សាទាំងកំរោលហក់មកវាយ ទាត់ធាក់ និងដាល់ចំផ្ទៃមុខ បណ្តាលឲ្យរងរបួសធ្ងន់ហូរ ឈាមខ្លាំង និងកូដករខ្លះសន្លប់បាត់ស្មារតី។

- **នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២៖** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស ប្រចាំកម្ពុជា បានមកឃ្លាំមើលការធ្វើកូដកម្មឈរតវ៉ា លើកបដា និងស្រែកទាមទារនៅមុខក្រុមហ៊ុន

[5] អាស៊ីសេរីថ្ងៃទី០២-មិថុនា-២០២២ https://www.rfa.org/khmer/news/human-rights/sok-ratana-is-in-great-pain-after-authorities-violently-suppressed-the-abortion-06022022060516.html

ណាហ្គាវើលដ៍ ដើម្បីរកដំណោះស្រាយ ដោយសន្តិវិធី មិនមានការរារាំង និងហិង្សាពីកម្លាំងសមត្ថកិច្ច។

- **ចាប់ពីខែសីហា ដល់បំណាច់ខែធ្នូ ឆ្នាំ២០២២** កូដករធ្វើកូដកម្ម បីថ្ងៃ ក្នុងមួយសប្តាហ៍ចាប់ពីម៉ោង ១០ព្រឹក ដល់ម៉ោង០៥ល្ងាច ដោយមិនមាន ការចាប់បញ្ជូនតាមរថយន្ត ទៅដាក់ចោលនៅជាយក្រុងទេ គឺកូដករអាចធ្វើកូដកម្មនៅមុខក្រុមហ៊ុនណាហ្គាវើលដ៍ហើយនៅ ខែកញ្ញា ឆ្នាំ២០២២ ក្រុមកូដករបានបោះតង់ និងធ្វើម្ហូប-អាហារនៅនឹងកន្លែងកូដកម្ម ទោះបី ជាពេលខ្លះ មានការប៉ះទង្គិចគ្នាជាមួយសន្តិសុខក្រុមហ៊ុន។

- **នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២៖** ក្រុមហ៊ុនណាហ្គាវើលដ៍ បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុមកូដករពីបទរំលោភលំនៅដ្ឋាន ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដោយចេតនា និងបង្ខាំងខុសច្បាប់។



ក្រុមកូដករបោះតង់ និងធ្វើម្ហូប (១៦-កញ្ញា-២០២២)

- **នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០២២៖** សាលារាជធានីភ្នំពេញ បានចេញប្រកាសផ្អាកធ្វើកូដកម្មជាបន្ទាន់ រយៈពេលមួយសប្តាហ៍ ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី១៣ វិច្ឆិកា អំឡុងពេលព្រះរាជពិធីបុណ្យអុំទូក និងកិច្ចប្រជុំកំពូលអាស៊ាន ប៉ុន្តែក្រុមកូដករ នៅតែបន្តធ្វើកូដកម្មដូចធម្មតា ដែលជាកត្តានាំឲ្យមានដីកាកោះហៅកូដករទៅសួរនាំនៅតុលាការរាជធានីភ្នំពេញជាបន្តបន្ទាប់មានចំនួនសរុប២១នាក់ មកដល់បំណាច ខែធ្នូ ឆ្នាំ ២០២២។

| ក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធសេរីភាពមូលដ្ឋាន | |
|---|---|
| រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | - មាត្រា៤១៖ "ប្រជាពលរដ្ឋខ្មែរ មានសេរីភាព ខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន..."<br>- មាត្រា៣៧ ចែងថា៖ សិទ្ធិក្នុងការបញ្ចេញមតិ តាមរយៈការធ្វើកូដកម្ម និងធ្វើបាតុកម្ម ដោយសន្តិវិធី ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | - មាត្រា១៩៖ ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។<br>- មាត្រា២២(១)៖ ជនគ្រប់រូបមានសិទ្ធិចូលរួម ជាសមាគមន៍ដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលរួមជាសមាជិកសហជីពដើម្បីការពារផលប្រយោជន៍ខ្លួន។ |
| សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស | - មាត្រា១៩៖ មនុស្សគ្រប់រូប មានសិទ្ធិសេរីភាព ក្នុងការមានមតិ និងការសម្តែងមតិ។ |
| គោលដៅអភិវឌ្ឍប្រកបដោយចីរភាព | - គោលដៅទី១៦(ចំនុចដៅ១០)៖ ធានាការទទួលបានព័ត៌មានជាសាធារណៈ និងការពារសេរីភាពជាមូលដ្ឋាន អនុលោមតាមបញ្ញត្តិជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។ |
| យន្តការពិនិត្យជាសកលតាមកាលកំណត់(UPR) | - ជុំទី៣មានប្រទេសបណ្តាប្រទេស ជារដ្ឋសមាជិកចំនួន១៩ប្រទេស៖ បារាំង អាល្លឺម៉ង់ កូឡុំប៊ី កូស្តារីកា ន័រវែស អ៊ីស្លង់ អេស្បាញ អ៊ីតាលី ស៊ុយអ៊ែត ស្វីស សហរដ្ឋអាមេរិក អាហ្សង់ទីន ប្រេស៊ីល កាណាដា ជប៉ុន ដាណឺម៉ាក លីទុយអានី ក្រិក និងប្រទេសហូឡង់ ជាដើម បានផ្តល់ អនុសាសន៍ ដល់រដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធការធានានូវសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គមតាមអ៊ីនធ័រណែត ជាពិសេសធានាថាមិនមានការបំភិតបំភ័យ ការរារាំងតាមរយៈការរឹតត្បឹតទៅលើសេរីភាពប្រមូលផ្តុំ ឬបញ្ចេញមតិ។ ដូចជា៖ **ប្រទេសបារាំង** ផ្តល់អនុសាសន៍ ឲ្យរដ្ឋាភិបាលកម្ពុជា ធានានូវសេរីភាព |

| | |
|---|---|
| | បញ្ចេញមតិសម្រាប់ពលរដ្ឋ និងអ្នកសារព័ត៌មានទាំងអស់ រួមទាំងតាមអ៊ិនធ័រណែត ដោយធ្វើការកែលម្អការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកចុងក្រោយ ក៏ដូចជាប្រកាសអន្តរក្រសួង កាលពីខែឧសភា ឆ្នាំ២០១៨ បានអនុញ្ញាត ឲ្យមានការតាមឃ្លាំមើលមាតិកា ខ្លឹមសារ អត្ថបទ តាមអ៊ីនធ័រណេត។ **ប្រទេសស្វីស** ធានាថា ពលរដ្ឋទាំងអស់ អាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម។ **ប្រទេសដាណឺម៉ាក** ការធ្វើច្បាប់បទប្បញ្ញត្តិ និងគោលនយោបាយនានា ស្តីពីសេរីភាពបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំ ជាសាធារណៈស្របទៅតាម កតិកាសញ្ញា អន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ។ |
| សេចក្តីថ្លែងការណ៍ភ្នំពេញអំពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០១២ | - (ចំនុច២៣)៖ មនុស្សម្នាក់ៗមានសិទ្ធិសេរីភាពនៃមតិនិងសិទ្ធិសេរីភាពក្នុងការសម្តែងមតិ រួមមានសេរីភាព ក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងមានសិទ្ធិស្វែងរក ទទួលយក និងចែកចាយព័ត៌មានដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ ឬតាម បណ្តាញព័ត៌មានផ្សេងទៀតណាមួយដែលជាជម្រើសរបស់ខ្លួន។ |
| អនុសាសន៍គណៈកម្មការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) | - កម្មាធិការលុបបំបាត់ ការរើសអើង ប្រឆាំងនឹងស្ត្រី (ចំនុចទី១៩[6])៖ CEDAW/C/KHM/CO/6 (CEDAW 2019) រដ្ឋភាគីធានាយ៉ាងពេញលេញនូវសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សស្ត្រី មេដឹកនាំសហជីព សកម្មជនដីធ្លីនិងបរិស្ថាន និងសមាជិកគណបក្សប្រឆាំងនយោបាយ ជាពិសេសសិទ្ធិរបស់ពួកគេ ក្នុងការបញ្ចេញមតិ ការជួបជុំ និងសមាគមដោយគ្មានការយាយីការឃ្លាំមើល ឬការរឹតត្បឹតមិនសមរម្យផ្សេងទៀត។ |

[6] CEDAW - https://documents-dds-ny.un.org/doc/UNDOC/GEN/N19/363/06/PDF/N1936306.pdf?OpenElement

| | |
|---|---|
| | - កម្មាធិការកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ២១[7]) CCPR/C/KHM/CO/2(CCPR 2015)៖ រដ្ឋភាគី គួរតែធានាមនុស្សគ្រប់រូប អាចអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសមាគមរបស់ខ្លួនដោយសេរី ស្របតាមមាត្រា១៩ និង២២ នៃកតិកាសញ្ញា - មតិទូទៅរបស់គណៈកម្មាធិការ លេខ៣៤(២០១១) ស្តីពីសេរីភាពបញ្ចេញមតិនិងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពចំនុចដៅទី១៦.១ ១៦.១០, និង១៦.៣។ |

## ១.២. លំហសេរីភាពនយោបាយ

សេរីភាពនយោបាយ ត្រូវការជាចាំបាច់សិទ្ធិសេរីភាពមូលដ្ឋាន ដែលបង្ហាញអំពី បរិយាកាសការអនុវត្តន៍លទ្ធិប្រជាធបតេយ្យ និងនីតិរដ្ឋ ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ពិសេសជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ។ ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណិតទី៥ ថ្ងៃទី៥-មិថុនា-២០២២ សមាគមអាដហុកសង្កេតឃើញមានភាពមិនប្រក្រតីមួយចំនួនដូចជា[8]៖

- **មុនពេលបោះឆ្នោត៖** យោងតាមរបាយការណ៍ បរិយាកាសនយោបាយ ការបោះឆ្នោត២០២២ សមាគមអាដហុកបានបង្ហាញថា៖ មានចំនួន ៨១ករណី បានកើតឡើងក្នុង ១៧ខេត្ត ៥០ស្រុក-ក្រុង ៦០ឃុំ-សង្កាត់ផ្សេងៗគ្នាមានដូចជា គំរាមកំហែងតាមរយៈប្រព័ន្ធតុលាការ បដិសេធលុបឈ្មោះបេក្ខជនចេញពីបញ្ជីឈរឈ្មោះគណបក្ស គំរាម(តាមបណ្តាញសង្គម)បង្ករបួសស្នាម គំរាមឲ្យលាឈប់ពីបញ្ជីឈរឈ្មោះបេក្ខភាពគណបក្ស បំផ្លាញស្លាកសញ្ញាគណបក្ស រារាំងការលើកស្លាកសញ្ញាគណបក្ស និងរឹតត្បឹតសេរីភាពជួបជុំសកម្មជនគណបក្ស។

[7] ICCPR - https://documents-dds-ny.un.org/doc/UNDOC/GEN/G15/082/72/PDF/G1508272.pdf?OpenElement
[8] របាយការណ៍ភាសាអង់គ្លេស https://www.adhoccambodia.org/8110-2/ និងភាសាខ្មែរ https://www.adhoccambodia.org/km/8110-2/

- **អំឡុងពេលបោះឆ្នោត៖** ការរារាំងអ្នកសង្កេតការណ៍ មិនឲ្យថតដំណើរការរាប់សន្លឹកឆ្នោត មានការបិទប្រកទីតាំងការិយាល័យ បិទទ្វារបង្អួចការិយាល័យក្នុងពេលរាប់សន្លឹកឆ្នោត ការបង្ហាញវត្តមានអាជ្ញាធរមូលដ្ឋានដូចជាមេភូមិ ឃុំ នគរបាលប៉ុស្តិ៍ អង្គុយខាងមុខការិយាល័យបោះឆ្នោត ចាំកត់ត្រាឈ្មោះអ្នកមកបោះឆ្នោត។
- **ក្រោយការបោះឆ្នោត៖** ការបន្តចាប់ឃុំខ្លួនសកម្មជននយោបាយ ការប្រកាសផ្តន្ទាទោសអ្នកនយោបាយ និងសកម្មជនសិទ្ធិមនុស្សទ្រង់ទ្រាយធំរហូតដល់ចំនួន៦១នាក់ ការប្តឹងលោក**សុនឆ័យ** ថ្នាក់ដឹកនាំគណបក្សភ្លើងទៀនទៅតុលាការ ដោយគណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពាក់ព័ន្ធបទបរិហាកេរ្តិ៍ មេឃុំចំណារលើ ខេត្តកំពង់ធំ ទើបជាប់ឆ្នោតថ្មី ត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាការដោយចោទពីបទ ប្លន់ កាលពីជាងដប់ឆ្នាំមុន ការលុបឈ្មោះចៅសង្កាត់រងទើបជាប់ឆ្នោត នៅសង្កាត់ច្បារអំពៅ ការលបវាយអនុប្រធានក្រុមការងារគណបក្សភ្លើងទៀន ខណ្ឌពោធិ៍សែនជ័យ និងការកោះហៅជំទប់ទី២ គណបក្សភ្លើងទៀនម្នាក់ ដោយតុលាការខេត្តត្បូងឃ្មុំ ចូលបំភ្លឺពីបទបរិហារកេរ្តិ៍។ សកម្មជនសង្គម សកម្មជននយោបាយចំនួន ៤០នាក់[9] ដែលប្រព្រឹត្តដោយជនមិនស្គាល់មុខបង្កហឹង្សា បណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ជនរងគ្រោះម្នាក់ស្លាប់ ខ្លះធ្លាក់ខ្លួនពិការ ដោយមានការលួចវាយប្រហារពីក្រោយខ្នង ហើយភាគច្រើនមកដល់ពេលនេះសមត្ថកិច្ចនៅមិនទាន់បានចាប់ខ្លួនជនដៃដល់យកមក ផ្តន្ទាទោសតាមច្បាប់នោះទេ។ លើសពីនេះទៀត អស់រយៈពេលជិត២ខែគិតត្រឹមថ្ងៃទី២១ខែសីហាឆ្នាំ២០២២ ក្រោយពីការប្រកាស សុពលភាពចូលកាន់តំណែងក្រុមប្រឹក្សាឃុំ/សង្កាត់ មកពីគណបក្ស ភ្លើងទៀនប្រមាណ៣០% មិនទាន់ទទួលបានការបែងចែកតួនាទីភារកិច្ច មានសម្លៀកបំពាក់ឯកសណ្ឋាន និងកន្លែងអង្គុយធ្វើការនៅឡើយទេ។

| **ក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធលំហរសេរីភាពនយោបាយ** | |
|---|---|
| រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | - **មាត្រា៣១(កឋាខ័ណ្ឌទី២)៖**ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ច ដូចគ្នាទាំងអស់ដោយ |

[9] RFA-15 Aug 2022: https://streamer1.rfaweb.org/stream/KHM/KHM-2022-0814-1230.mp3

| | |
|---|---|
| | ឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ...។<br>- **មាត្រា៣៤ថ្មី៖** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឲ្យគេបោះឆ្នោត។<br>- **មាត្រា៣៥៖** ពលរដ្ឋទាំងពីភេទ មានសិទ្ធចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយណា របស់ប្រជាពលរដ្ឋត្រូវបានទទួល ការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ |
| ច្បាប់ស្តីពីគណបក្សនយោបាយ | - **មាត្រា៤៖** គ្រប់គណបក្សនយោបាយ មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបុព្វសិទ្ធិ និងការយកចិត្តទុកដាក់ ដោយស្មើភាពគ្នា ពីរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់។<br>- **មាត្រា៥៖** ការចូលជាសមាជិក របស់គណបក្សនយោបាយណាមួយគឺ ជាការជ្រើសរើសផ្ទាល់ខ្លួន ដោយសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប...គ្មានជនណាម្នាក់ ត្រូវបានគេដកហូតសិទ្ធិ ក្នុងការអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិវិជ្ជាជីវៈដោយសារមូលហេតុជននោះជាសមាជិក ឬមិនមែនជាសមាជិកគណបក្សនយោបាយណាមួយដែលបង្កើតឡើងដោយស្របច្បាប់នោះទេ។<br>- **មាត្រា១៥ (កឋាខណ្ឌទី២)៖** បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកំលាំង នគរបាល អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ |
| ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | - **មាត្រា៦៩៖** ស្លាកសញ្ញាគណបក្សនយោបាយ អាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។ |

| | |
|---|---|
| | - **មាត្រា៧១៖** គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។<br>- **មាត្រា៧៩៖** ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោត..<br>- **មាត្រា១១៨៖** មិនអនុញ្ញាតឲ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោត ក្នុងពេលដែល អ្នកបោះឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែងតែមានការអនុញ្ញតអនុលោម តាមបទប្បញ្ញត្តិនៃច្បាប់នេះ។ |
| សេចក្តីណែនាំស្តីពីការលើកស្លាកសញ្ញាគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១៧ | - **ចំណុច២៖** ការលើកស្លាកសញ្ញាគណបក្សនយោបាយ នៅទីសាធារណៈត្រូវឈរលើគោលការណ៍ ស្មើភាពលំដាប់មុនក្រោយនិងលើកស្លាកនៅលំនៅឋានឯកជន ឬទីកន្លែងឯកជន ត្រូវមានការយល់ព្រមពីម្ចាស់កន្លែងនោះ។ |
| សេចក្តីជូនដំណឹងក្រសួងមហាផ្ទៃលេខ៣១៦សជណថ្ងៃទី០៧-កុម្ភៈ-២០២២ | - ស្តីពីការបង្កលក្ខណៈងាយស្រួល ដល់គ្រប់គណបក្សនយោបាយ ធ្វើសកម្មភាពចូលរួមក្នុង ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ដូចជាៈ ការលើកស្លាកសញ្ញាគណបក្ស និងការជួបប្រជុំ នយោបាយ។ |
| សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានឆ្នាំ២០១២ | - **មាត្រា២៥៖** សិទ្ធិចូលរួម ក្នុងជីវភាពនយោបាយ នៃប្រទេសជាតិរបស់ខ្លួន។ |
| យន្តការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ (UPR-2019) | - **ប្រទេសន័រវែស៖** បានផ្តល់អនុសាសន៍ប្រទេសកម្ពុជា ស្តារឡើងវិញនូវលំហប្រជាធិបតេយ្យ និងនយោបាយ ដោយធានានូវការចូលរួមសំរាប់គណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ |

## ១.៣. ភាពមិនប្រក្រតីនៅពីក្រោយការផ្តិតស្នាមមេដៃលើញត្តិគាំទ្រ

"ជ្រុងមួយនៃយុត្តិធម៌សង្គម ក្នុងការបំពេញភារកិច្ចរបស់មន្ត្រីរាជការ ជាពិសេសមន្ត្រីថ្នាក់មូលដ្ឋាន"




នៅចន្លោះពាក់កណ្តាលខែតុលា និងដើមខែវិច្ឆិកា មានការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា៖ ទូរទស្សន៍ បណ្តាញសង្គម នូវញត្តិថ្កោលទោសទណ្ឌិត សម រង្ស៊ី ជាជនក្បត់ជាតិ៣ជំនាន់ ដែលញត្តិនោះចេញមកពីគ្រប់ក្រសួង-ស្ថាប័ន ទាំងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ ព្រមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិមានខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ផងដែរ។

សមាគមអាដហុក បានសង្កេតឃើញថា មានបញ្ហាមិនប្រក្រតីមួយចំនួន នៅពីក្រោយការផ្តិតស្នាមមេដៃ គាំទ្រញត្តិថ្កោលទោស ជាពិសេសក្នុងក្របខណ្ឌរដ្ឋបាលអាជ្ញាធរឃុំ-សង្កាត់ ដែលមានអាសនៈសមាជិកគណបក្សភ្លើងទៀន ជាប់ឆ្នោតជាជំទប់ទី១ ឬជំទប់ទី២ឬក្រុមប្រឹក្សាឃុំសង្កាត់*(គណបក្សភ្លើងទៀនទទួលបានអាសនៈសរុបចំនួន ២,១៩៨អាសនៈ)*។ អំឡុងពេលនោះ សមាគមអាដហុកទទួលបានព័ត៌មានតាមរយៈការដាក់ពាក្យ ជាលាយលក្ខអក្សរពាក់ព័ន្ធនឹងករណីគម្រាមកំហែង បង្ខំឲ្យផ្តិតស្នាមមេដៃគាំទ្រលើញត្តិថ្កោលទោសទណ្ឌិត សម រង្ស៊ី ជាជនក្បត់ជាតិ៣ជំនាន់។ ភាគច្រើននៃព័ត៌មានទទួលបាន (ជាង៩៧%) បានចោទប្រកាន់លើមេឃុំ-ចៅសង្កាត់ ជាអ្នកបង្ខិតបង្ខំឲ្យផ្តិតមេដៃគាំទ្រ លើញត្តិថ្កោលទោស ដោយគំរាមថា បើមិនព្រមផ្តិតស្នាមមេដៃលើញត្តិគាំទ្រទេ ៖

- ប្រយ័ត្នគេរំលាយគណបក្សចោលដូចកាលឆ្នាំ២០១៧ទៀត មិនបានចូលរួមបោះឆ្នោតឆ្នាំ២០២៣ ហើយអាចបាត់បង់តួនាទី បាត់បង់ការងារ គ្មានប្រាក់ខែដូចឆ្នាំ២០១៧។
- ការគាំទ្រទណ្ឌិត សម រង្ស៊ី ស្មើនឹងជនក្បត់ជាតិ ដូច្នោះត្រូវប្រឈមមុខផ្លូវច្បាប់។
- ប្រយ័ត្នត្រូវគេចាប់ដាក់គុក
- បើមានបញ្ហាអ្វីកើតឡើងគេ "មេឃុំ-ចៅសង្កាត់ និង/ឬ អភិបាលស្រុក" មិនទទួលខុសត្រូវឡើយ

ព័ត៌មានដែលទទួលបានមាន ៣៣ករណី មកពីបេក្ខភាព១៦០នាក់ ដែលមានអាសនៈ ក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ គណបក្សភ្លើងទៀន ស្ថិតនៅក្នុង៦៣ឃុំ-សង្កាត់ នៃខេត្តចំនួន១១ គឺ "ខេត្តកណ្ដាល បាត់ដំបង តាកែវ កំពត កំពង់ស្ពឺ កំពង់ចាម កោះកុង ស្ទឹងត្រែង ព្រៃវែង ព្រះសីហនុ និងខេត្តសៀមរាប"។

## ១.៤. ករណីទារុណកម្ម និងនិទណ្ឌភាព

"ជ្រុងមួយ នៃយុត្តិធម៌សង្គម ក្នុងការបំពេញភារកិច្ចរបស់នគរបាលយុត្តិធម៌"

នៅអំឡុងឆ្នាំ២០២២ ឆ្លងតាមការអង្កេត សមាគមអាដហុក ទទួលបានព័ត៌មានការធ្វើទារុណកម្មចំនួន១៤ករណីដែលមានជនរងគ្រោះដោយសារអំពើទារុណកម្មចំនួន២៧នាក់(ស្រីម្នាក់) បានកើតឡើងក្នុងខេត្ត-ក្រុងទាំងប្រាំបីគឺ ខេត្តសៀមរាប ពោធិសាត់ ឧត្តរមានជ័យ កំពង់ស្ពឺ បន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ និងរាជធានីភ្នំពេញ។

- **ទីកន្លែង និងអ្នកប្រព្រឹត្តៈ** ក្នុងចំណោម១៤ករណីនេះ ការធ្វើទារុណកម្មដោយហឹង្សា ត្រូវបានធ្វើឡើងនូវក្នុងទីកន្លែង ដែលជាអាគាររដ្ឋបាលសាធារណៈរបស់រដ្ឋដូចជាៈ ប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់ អធិការដ្ឋានស្រុក-ខណ្ឌ ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ពន្ធនាគា(ត្រពាំងថ្លុង) ហើយអ្នកដែលប្រើហឹង្សាធ្វើទារុណកម្មគឺ មន្ត្រីយុត្តិធម៌ក្នុងតួនាទី មានដូចជា មន្ត្រីនគរបាលរដ្ឋបាលប៉ុស្តិ៍ មន្ត្រីនគរបាលអធិការដ្ឋាន មន្ត្រីនគរបាលស្នងការខេត្ត មន្ត្រីកងរាជអាវុធហត្ថខេត្ត ព្រមទាំងមន្ត្រីអនុរក្សពន្ធនាគារ និងអ្នកទោសដូចគ្នាក្នុងពន្ធនាគារផងដែរ។

- **គោលបំណង និងវិធីសាស្ត្រ៖**



- **បង្ខំឲ្យសារភាព៖**នៅពេលសួរចម្លើយជនសង្ស័យ បទល្មើសចោរកម្ម បទល្មើសបង្កប្លួសស្នាម បទល្មើស គ្រឿងញៀន។ ករណីនេះ មុនកសាងសំណុំរឿងបញ្ជូនទៅតុលាការនគរបាលយុត្តិធម៌បានប្រើដៃ-ប្រើជើងទះទាត់ធាក់លើរាងកាយ ប្រើកៅអីជ័រវាយពីក្រោយខ្នង និងករណីខ្លះប្រើអាវុធខ្លីវាយក្បាលជនសង្ស័យ ទាំងដៃជាប់ខ្នោះដោយគម្រាមបន្ថែមទៀតថា បើនៅតែមិនឆ្លើយសារភាពទៀតគេ(អ្នកសួរចម្លើយ) នឹងធក់ខ្សែភ្លើង ហើយចាប់ដកក្រចក។ តាមព័ត៌មានបញ្ជាក់ថា ដោយមានការឈឺចុកចាប់ខ្លាំងពេកជនសង្ស័យទ្រាំមិនបានក៏ឆ្លើយសារភាព និងផ្តិតមេដៃ ទទួលស្គាល់លើកំណត់ហេតុសាកសួរ ទាំងឈឺចាប់ពេញខ្លួនប្រាណ។ នៅក្នុងនោះ មានជនសង្ស័យ អំពើចោរកម្មម្នាក់បានស្លាប់ ក្រោយពេលបញ្ជូនដល់មន្ទីរពេទ្យ ដោយនៅលើសាកសពមានបន្សល់ទុកនូវស្នាមប្លួសស្នាមជាំធ្ងន់ធ្ងរជាច្រើនកន្លែង ដែលជាស្នារដៃរបស់មន្ត្រីនគរបាលយុត្តិធម៌ពេលសួរចម្លើយ។
- **បង្ខំឲ្យសងប្រាក់៖** នៅស្នងការដ្ឋានខេត្ត នគរបាលយុត្តិធម៌បានអញ្ជើញអ្នកជំពាក់ប្រាក់ពីរនាក់ប្តីប្រព័ន្ធ) មកស្នងការដ្ឋាន ហើយចាប់ដាក់ខ្នោះដៃអ្នកទាំងពីរជាប់គ្នាដាក់ក្នុងបន្ទប់ចាក់សោរពីក្រៅ ហើយបង្ខំឲ្យសងប្រាក់ទៅម្ចាស់បំណុល រហូតដល់ប្តីស្រែកសុំឲ្យដោះខ្នោះចេញ ព្រោះប្រពន្ធរបស់គាត់មានអាការៈចង់ស្ទះបេះដូង ដោយសារទ្រាំនឹងការឈឺចាប់នេះមិនបាន ទាំងពីរនាក់ប្តីប្រពន្ធ បានឯកភាពគ្នា ព្រមសងប្រាក់ទៅម្ចាស់បំណុល ដោយកាត់ផ្ទេរប្លង់កម្មសិទ្ធិដីធ្លីរបស់ខ្លួន។ ទោះបីជាបានយល់ព្រមសងបំណុលហើយក៏ដោយ ក៏ពួកគាត់ មិនត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញឡើយ គឺពួកគាត់ត្រូវបំពេញកាតព្វកិច្ច បង់សេវា ឲ្យនគរបាលរាប់ពាន់ដុល្លារអាមេរិក ដោយពួកគាត់មិនមានប្រាក់ ខណៈនោះ គាត់បានទូរស័ព្ទទៅកូនរបស់គាត់តាមបញ្ជានគរបាល

នៅទីនោះ ដើម្បីរកខ្ចីប្រាក់អ្នកដទៃ ដោយយកទ្រព្យសម្បត្តិដាក់បញ្ចាំ បានយកមកបង់ឲ្យនគរបាលរួចសិន ទើបអនុញ្ញាតឲ្យវិលត្រឡប់ទៅផ្ទះវិញ។

- **បង្ក្រាបឲ្យបាក់ស្បាត៖** នៅពន្ធនាគារត្រពាំងផ្លុង ស្ថិតនៅក្នុងខេត្តកំពង់ចាម ដែលជាទីកន្លែង អនុរក្សពន្ធនាគារចូលរួម និងបណ្ដោយឲ្យអ្នកទោស ប្រើអំពើហិង្សាលើអ្នកជាប់ឃុំជាសកម្មជននយោបាយ "អតីតសមាជិកគណបក្សសង្គ្រោះជាតិ "១៤នាក់ ទើបបញ្ជូនទៅពីពន្ធនាគារព្រៃស ដែលក្នុងនោះ មានម្នាក់រងរបួសធ្ងន់ធ្ងរជាងគេ មានហូរឈាមតាមត្រចៀកខាងឆ្វេង និងស្ដាប់អ្វីមិនឮ។ ក្រោយពីត្រូវរងអំពើហិង្សារួចមក អ្នកជាប់ឃុំទាំងនោះ មានសភាពភិតភ័យ និង បាក់ស្បាត ស្ទាក់ស្ទើរក្នុងការនិយាយរាយការណ៍អំពីព្រឹត្តិការណ៍ឈឺចាប់ប្រាប់ទៅក្រុមគ្រួសាររបស់ខ្លួន។



- **ការមិនគោរពគោលការណ៍សិទ្ធិមនុស្សមូលដ្ឋាន៖** ករណីធ្វើទារុណកម្ម រហូតដល់ស្លាប់ជនល្មើសម្នាក់ នៅលើរថយន្តរបស់កងរាជអាវុធហត្ថខេត្ត អំឡុងពេលធ្វើដំណើរតាមផ្លូវទៅដល់ប៉ុស្តិ៍១០២ ករណីបង្ក្រាបល្បែងជល់មាន់អនទ្បាញ មួយកន្លែងមានទីតាំងផ្ទះលក់កាហ្វេស្ថិតនៅភូមិរូង ឃុំក្រវ៉ា ស្រុកបារ៉ាយ ខេត្តកំពង់ធំ បានដឹកនាំ ដោយក្រឡាបញ្ជីអយ្យការ នៃសាលាដំបូងខេត្ត រួមជាមួយកងរាជអាវុធហត្ថខេត្ត១៣នាក់ ប្រើរថយន្តពីរគ្រឿង។ ក្នុងពេលប្រតិបត្តិការកម្លាំង កងរាជអាវុធហត្ថខេត្ត ចាប់អ្នកលេងល្បែងចំនួន០៣នាក់ ហើយបានដាក់ខ្នោះដៃទាំងពីរទៅក្រោយ រុញចូលរថយន្ត ខណៈនោះជនសង្ស័យម្នាក់ មានអាការៈពិបាកដកដង្ហើមបានសុំអង្វរឲ្យដោះខ្នោះដៃសិន ហើយពេលនោះដែរ ក៏មានប្រជាពលរដ្ឋនៅជិតនោះ ជួយសុំអង្វរដោយសារឃើញទឹកមុខស្លេកស្លាំង ពិបាកដកដង្ហើម ប៉ុន្តែកម្លាំងកងរាជអាវុធហត្ថមិនព្រមទេ ហើយថែមទាំងនិយាយថា គាត់ធ្វើពុតទៀត ។ នៅពេល

កំពុងធ្វើដំណើរដោយឃើញអាការៈ មានសភាពកាន់តែស្លេកស្លាំង និងពិបាកដកដង្ហើម ជនសង្ស័យ០២នាក់ផ្សេងទៀត នៅលើរថយន្តជាមួយគ្នានោះ បានសុំអង្វរម្តងហើយ ម្តងទៀត ឲ្យកងរាជអាវុធហត្ថជួយគាត់ បើមិនដូច្នោះទេ គាត់អាចដាច់ខ្យល់ស្លាប់ឥឡូវហើយ ប៉ុន្តែកងរាជអាវុធហត្ថ នៅតែមិនអើពើជួយទេ រហូតដល់គាត់ដាច់ខ្យល់ស្លាប់ នៅលើរថយន្តដែលកំពុងធ្វើដំណើរតាមផ្លូវទៅប៉ុស្តិ៍១០២ តែម្តង។

ករណីនេះ ក្រុមគ្រួសារជនរងគ្រោះ បានដាក់ពាក្យបណ្តឹង ទៅសាលាដំបូងខេត្តកំពង់ធំ សូមជួយរកយុត្តិធម៌ និងផ្តន្ទាទោសជនប្រព្រឹត្តល្មើសតាមផ្លូវច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន៧ម៉ឺនដុល្លារអាមេរិក។ រយៈពេលប្រហែលមួយខែក្រោយមក បន្ទាប់ពីមានការរត់ការសម្របសម្រួល ប្រពន្ធជនរងគ្រោះ ក៏ព្រមដកពាក្យបណ្តឹង និងដកពាក្យសុំពឹងពាក់មេធាវី ដោយទទួលយកសំណងរដ្ឋប្បវេណីចំនួន១ម៉ឺន៥ពាន់ដុល្លារអាមេរិក ពីជនល្មើសដែលជាមន្ត្រីកងរាជអាវុធហត្ថខេត្តកំពង់ធំ។

| **ក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធអំពើទារុណកម្ម និងនិទណ្ឌភាព** | |
|---|---|
| រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | - មាត្រា៣៨៖ ច្បាប់ហាមឃាត់រាល់ការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។......ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាង នៃពិរុទ្ធ ភាពឡើយ។ |
| អនុសញ្ញាប្រឆាំងទារុណកម្មនិងពិធីសារបន្ថែម | - ទារុណកម្ម៖ គឺជាអំពើទាំងឡាយណា ដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី ដែលបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ក្នុងគោលបំណងទាំងឡាយណាដើម្បីយកព័ត៌មានពីជននោះ ឬតតិយជនម្នាក់ដាក់ទណ្ឌកម្មជននោះ ចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណាម្នាក់ បានប្រព្រឹត្ត ឬសង្ស័យថា បានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬ |

| | |
|---|---|
| | ដើម្បីមូលហេតុផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខ បង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែល បំពានតួនាទីជាផ្លូវការ។ |
| ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា | - មាត្រា២០១៖ ទារុណកម្ម ឬអំពើឃោឃៅ ដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ |

## ១.៥. បណ្តឹងបរិហារ

បណ្តឹងបរិហារ គឺជាបណ្តឹងមួយដែលធ្វើឡើង ដើម្បីបង្ហាញពីអត្ថិភាពនៃបទល្មើស ដែលកំពុងកើតមានឡើង ហើយត្រូវបានកំណត់ដោយច្បាប់ថា ជាបទល្មើស ក្នុងគោលបំណងធ្វើការបកអាក្រាតពីអំពើល្មើស ដែលជនប្រព្រឹត្តកំពុងប្រព្រឹត្ត ដើម្បីឲ្យអាជ្ញាធរសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីសាធារណៈដោយអាណត្តិតាមរយៈការបោះឆ្នោត ដែលមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យបទល្មើសប្រមូលយកព័ត៌មាន ឬកស្តុតាងធ្វើការទប់ស្កាត់និងចាប់ជនប្រព្រឹត្តផ្តន្ទាទោសតាមផ្លូវច្បាប់។បណ្តឹងបរិហារអាចធ្វើបានតាមរយៈតតីយជន ឬដោយមន្ត្រីសធារណៈដែលបានឃើញ និងបានដឹងអំពីបទល្មើសដែលកំពុងកើតមានឡើង។

ការធ្វើបណ្តឹងបរិហារ គឺជាសកម្មភាព គ្រាន់តែសេចក្តីរាយការណ៍ពីបទល្មើសដែលកំពុងកើតមានឡើង ឬ/និងក្រោយបានដឹង បានឃើញបទល្មើសនោះ។ អ្នកធ្វើបណ្តឹងបរិហារ មិនមែនជាម្ចាស់បណ្តឹងក្នុងដំណើរការនៃបណ្តឹងបរិហារនេះឡើយ ម្ចាស់បណ្តឹងពិតគឺ ព្រះរាជអាជ្ញា ដោយបំពេញកាតព្វកិច្ចលើមុខងាររបស់ខ្លួន ក្នុងការសម្របសម្រួល និងស៊ើបអង្កេតអំពីបទល្មើសនោះ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣៩ចែងថា ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណង ជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់ របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។

ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៤២ អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ ខ្លួនបានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈឹម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូននូវព័ត៌មាន លិខិត កំណត់ហេតុ រួមទាំងវត្ថុតាំងទាំងអស់ភ្ជាប់មកជាមួយផង។

មកត្រឹមបំណាច់ឆ្នាំ២០២២ សមាគមអាដហុក ទទួលបានព័ត៌មានតំណាងសហគមន៍ ចាប់ពីអំឡុងឆ្នាំ២០១៥ រហូតឆ្នាំ២០២១ តំណាងសហគមន៍ នៅក្នុងខេត្តចំនួន៥ បានរៀបចំឯកសារដាក់ពាក្យបណ្តឹងបរិហារចំនួន ១៩ករណី ទៅស្ថាប័នតុលាការ អំពីភាពមិនប្រក្រតិក្នុងការបំពេញតួនាទី របស់មន្ត្រីថ្នាក់ក្រោមជាតិ[10] និងអ្នកមានទ្រព្យសម្បត្តិ(ឧកញ៉ា) កាប់រានឈូសឆាយដីព្រៃរបស់រដ្ឋយកជាកម្មសិទ្ធិឯកជន ការលក់ទិញ ដីព្រៃសម្បទានសេដ្ឋកិច្ច និងប្តឹងពីការក្លែងលិខិតសាធារណៈចេញប្លង់កម្មសិទ្ធិដីធ្លីមិនប្រក្រតីសរុបជាងពីរម៉ឺនហិកតា៖

- **០៩ ករណី ខេត្តមណ្ឌលគីរី៖** ០៧ករណីបានទៅដល់សាលាឧទ្ធរណ៍ ក្នុងនោះ០៥ករណី តម្កល់មិនចាត់ការ។ ០២បណ្តឹងទៀត ត្រូវបានតំណាងអយ្យការកោះហៅដើមបណ្តឹង ចូលទៅឆ្លើយបំភ្លឺ ប៉ុន្តែមិនទាន់មានព័ត៌មានអំពីចំណាត់ការបន្តនៅឡើយទេ។
- **០៧ករណី ខេត្តរតនគីរី៖** ០២បណ្តឹង មិនទាន់មានចំណាត់ការពីអយ្យការនៅឡើយទេ ចាប់តាំងពីបានដាក់បណ្តឹងនៅឆ្នាំ២០១៦ ទោះបីជាដើមបណ្តឹងដាក់ពាក្យសុំឲ្យមានចំណាត់ការបន្ត។ ០១បណ្តឹង ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ តម្កល់មិនចាត់ការ។ ០៤បណ្តឹងទៀត ត្រូវបានតំណាងអយ្យការកោះហៅដើមបណ្តឹងចូលឆ្លើយបំភ្លឺប៉ុន្តែមិនទាន់មានព័ត៌មានអំពីចំណាត់ការបន្តនៅឡើយទេ។
- **០១ ករណី ខេត្តក្រចេះ៖** បន្តនីតិវិធីដល់សាលាឧទ្ធរណ៍
- **០១ ករណី ខេត្តត្បូងឃ្មុំ៖** កំពុងដំណើរការនីតិវិធីនៅតំណាក់កាលសាលាដំបូងខេត្ត
- **០១ ករណី ខេត្តកំពត៖** បន្តនីតិវិធីដល់សាលាឧទ្ធរណ៍

[10] មន្ត្រីសាលាខេត្ត មន្ត្រីមន្ទីរបរិស្ថាន មន្ត្រីមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយដី (អតីត)អភិបាលស្រុក-អភិបាលរងស្រុក នាយខណ្ឌរដ្ឋបាលព្រៃឈើ អធិការស្រុក មេឃុំ និងមេភូមិ។

| ក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធបណ្ដឹងបរិហារ | |
|---|---|
| រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | - មាត្រា៣៩៖ ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ |
| ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា | - មាត្រា៥២៨៖ អំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដែលមិនបានប្ដឹងបរិហារដល់អាជ្ញាធរ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតពីបទឧក្រិដ្ឋឬបទមជ្ឈឹមដែលខ្លួនបានដឹងនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាស នៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពីពីរលានរៀល ទៅប្រាំមួយលានរៀល។ |
| ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា | - មាត្រា៤២៖ អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមត្រូវតែជូនដំណឹងភ្លាម ទៅដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់ជាមួយផង។<br>- មាត្រា៣២៩៖ អ្នកប្ដឹងបរិហារដែលបានទទួលរង្វាន់ពីបណ្ដឹងបរិហាររបស់ខ្លួន ក៏អាចត្រូវបានតុលាការស្ដាប់ចម្លើយយកជាព័ត៌មានបានដែរ។ |

# អនុសាសន៍ផ្នែកសិទ្ធិមនុស្ស

របាយការណ៍ឆ្នាំ២០២២ បានបង្ហាញថា ករណីរំលោភសិទ្ធិមនុស្សនៅកម្ពុជា កាន់តែមានសភាពធ្ងន់ធ្ងរ និងកើនឡើង៣៩២ករណី បើធៀបនឹងឆ្នាំ២០២១ មានត្រឹមតែ១៥៧ករណីប៉ុណ្ណោះ ជាពិសេសករណីទាំងនោះរួមមានការគំរាមកំហែងសកម្មភាពនយោបាយ ការរឹតត្បិតសេរីភាពមូលដ្ឋាន អំពើទារុណកម្ម និងនិទណ្ឌភាពជាដើម។

ដើម្បីចូលរួមសកម្មភាពប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សគ្រប់ទម្រង់ ក្នុងគោលដៅសន្តិភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សមាគមអាដហុកមានអនុសាសន៍មួយចំនួនដូចជា៖

## សំពាសេរីភាពមូលដ្ឋាន

១. រដ្ឋាភិបាលត្រូវពង្រឹងការអនុវត្តន៍ច្បាប់-បទដ្ឋានគតិយុត្តិជាធរមាន ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ជាពិសេសត្រង់មាត្រា៣៧ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា១៩ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

២. ក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំអាជ្ញាធរមូលដ្ឋានឲ្យឈប់ឃ្លាំមើល តាមដាន សួរនាំ-ថតរូបសុំបញ្ជីវត្តមាននូវសកម្មភាពការងារសហគមន៍ និងតម្រូវឲ្យសហគមន៍រាយការណ៍ពេលមុនទៅចូលរួម និងត្រឡប់ពីចូលរួមសកម្មភាពជាមួយអង្គការសង្គមស៊ីវិលវិញ។

៣. ក្រសួងមហាផ្ទៃ ធ្វើការណែនាំអាជ្ញាធរមូលដ្ឋាន ឲ្យយល់អំពីអ្វីដែលហៅថា បរិហារ បំពុលសង្គម Facebookនិយាយអំពីបញ្ហាដីធ្លី និងព្រៃឈើ។

## សំពាសេរីភាពនយោបាយ

១. ដាក់វិន័យ ឬទោសទណ្ឌតាមច្បាប់ ចំពោះជនណា ឬមន្ត្រីណា ដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសត្រង់មាត្រា៣១ មាត្រា៣៤ និងមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ មាត្រា៤ មាត្រា៥ និងមាត្រា១៥ និងច្បាប់ស្តីពីការបោះឆ្នោតពាក់ព័ន្ធនានា។

២. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ត្រូវដោះស្រាយនូវរាល់វិវាទពាក់ព័ន្ធកើតមានឡើង ដោយឈរលើគោលការណ៍ ឯករាជ្យ អព្យាក្រឹត្យ និងដោយមិនរើសអើងបក្សនយោបាយ។ ចំពោះវិវាទទាក់ទងការបោះឆ្នោត គប្បីត្រូវតែដោះស្រាយដោយច្បាប់បោះឆ្នោត ។

៣. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ពង្រឹងសមត្ថភាព មន្ត្រីមូលដ្ឋានថ្នាក់ក្រោមជាតិអំពីនីតិវិធីការបោះឆ្នោត ការដោះស្រាយវិវាទ ច្បាប់ បទដ្ឋានគតិយុត្តិពាក់ព័ន្ធការបោះឆ្នោត និងក្រមសីលធម៌មន្ត្រីរាជការ ដោយឯករាជ្យ និងអព្យាក្រឹត្យ។

៤. ក្រសួងមហាផ្ទៃ ធ្វើសេចក្ដីណែនាំមន្ត្រីមូលដ្ឋានថ្នាក់ក្រោមជាតិ ឲ្យបញ្ឈប់រាល់សកម្មភាព រំខាន-បំភិតបំភ័យ គំរាមកំហែង តាមគ្រប់រូបភាព និងគ្រប់ទម្រង់ដែលអាចបង្ហាញជាសញ្ញាបំភិតបំភ័យចំពោះសកម្មជនគណបក្សនយោបាយ និងអ្នកដែលមានមតិផ្ទុយ ក៏ដូចជាប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោត។

៥. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយជាពិសេសនៅតាមទីជនបទ-ជនជាតិដើមភាគតិចអំពីការពិនិត្យឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត និងឯកសារពាក់ព័ន្ធនានា សំរាប់ការបោះឆ្នោត។

៦.គណកម្មាធិការរៀបចំការបោះឆ្នោតជាតិ ចេញសេចក្ដីណែនាំដល់មន្ត្រីទទួលខុសត្រូវតាមមណ្ឌលបោះឆ្នោត ការិយាល័យបោះឆ្នោតមានតម្លាភាព ក្នុងការរាប់សន្លឹកឆ្នោតដូចជា បិទច្រកទីតាំងការិយាល័យ និង/ឬបិទទ្វារបង្អួចការិយាល័យរាប់សន្លឹកឆ្នោត មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋមើលការរាប់សន្លឹកឆ្នោត។

៧. ក្រសួងមហាផ្ទៃត្រូវត្រួតពិនិត្យ និងដោះស្រាយជាបន្ទាន់ឲ្យបញ្ឈប់ការរើសអើងគ្រប់ទម្រង់គណបក្សនយោបាយដែលបានជាប់ឆ្នោត ដោយរៀបចំឲ្យបេក្ខជនជាប់ឆ្នោតគ្រប់គណបក្សនយោបាយអាចចូលបំពេញតួនាទី ភារៈកិច្ចកិច្ច តាមច្បាប់កំណត់។

៨.ក្រសួងយុត្តិធម៌ពង្រឹងយុត្តិធម៌សង្គមលុបបំបាត់អំពើនិទណ្ឌភាពគ្រប់ទម្រង់ ជាពិសេសអំពើល្មើសដែលប្រព្រឹត្តឡើងក្នុងគោលដៅនយោបាយ ដូចជាការបង្ករបួសស្នាមសកម្មជននយោបាយ និងការធ្វើទុក្ខបុកម្និញសកម្មជននយោបាយតាមប្រព័ន្ធតុលាការជាដើម។

## ករណីទារុណកម្ម និងនិទណ្ឌភាព

១.ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ត្រូវដាក់ទោសទណ្ឌតាមច្បាប់ជាធរមានចំពោះមន្ត្រីទាំងឡាយណាដែលប្រើអំណាច-តួនាទីភារកិច្ច របស់ខ្លួនជានគរបាលយុត្តិធម៌ ធ្វើទារុណកម្មគ្រប់រូបភាពដល់ជនសង្ស័យ-ជនល្មើស ក្នុងគោលបំណងបង្ខំឲ្យសារភាព ដែលសកម្មភាពទាំងនោះប្រឆាំងនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសត្រង់មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមាត្រា២០១ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម។

## បណ្ដឹងបរិហារ

១. រដ្ឋាភិបាល ជាពិសេសក្រសួងមហាផ្ទៃ គួរតែធ្វើយុទ្ធនាការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយ ព្រមទាំងបង្កើនសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ អំពីគោលការណ៍បណ្ដឹងបរិហារ និងការអនុវត្តន៍ច្បាប់ជាធរមាន ជាពិសេសត្រង់មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា៥២៨មាត្រា៥២៩ និងមាត្រា៥៣០ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា មាត្រា៤២។

# ផ្នែកទី២៖ ផ្នែកសិទ្ធិដីធ្លី




តាមការអង្កេតវិវាទដីធ្លី នៅតែបន្តកើតមានឡើងឥតឈប់ឈរ ទន្ទឹមនិងវិវាទរាំរ៉ៃមួយចំនួនធំមិនទាន់បានដោះស្រាយនៅឡើយ ខណៈវិវាទថ្មីៗទៀតបានកើតឡើងជាបន្តបន្ទាប់ នៅក្នុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញ វិវាទដីធ្លីកើតឡើងចំនួន៨៤ករណី ដែល៥០% នៃវិវាទគឺជាករណីរំលោភដោយបុគ្គលមានអំណាច ដែលនាំឲ្យប៉ះពាល់ដល់ជនរងគ្រោះផ្ទាល់ចំនួន៧,១៤១គ្រួសារ ស្មើ៣៦,៧៦៦នាក់ ដីវិវាទចំនួន៩,៨៣១.១១ហិកតា ជាង៩៧% នៃវិវាទត្រូវបានអូសបន្លាយការរកដំណោះស្រាយរហូតមកដល់បំណាច់ឆ្នាំ២០២២នេះ។

ភាគច្រើននៃវិវាទរកឃើញ បានកើតឡើងក្នុងខេត្តចំនួន១៥ដូចជា៖ កោះកុង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ ព្រះសីហនុ បន្ទាយមានជ័យ ពោធិសាត់ ព្រះវិហារ ភ្នំពេញ មណ្ឌលគិរី រតនគិរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង និងឧត្តរមានជ័យ។

**តារាងទិន្នន័យ**[11]

| | **ឆ្នាំ២០២០** | **ឆ្នាំ២០២១** | **ឆ្នាំ២០២២** |
|---|---|---|---|
| ចំនួនករណីវិវាទ | ១៨២ | ១៦៩ | ៨៤ |
| ចំនួនជនរងគ្រោះ | ៧៧,៣៦១ | ៦១,៤៦៩ | ៣៦,៧៦៦ |
| ចំនួនដីប៉ះពាល់(ហិចតា) | ៥៧,០៨៦.៨៥ | ៥២,៦០១ | ៩,៨៣១.១១ |
| ចំនួនករណីខ្ពស់ជាងគេ | ៩៣ ករណី រំលោភដោយ បុគ្គលមានអំណាច | ៦៦ ករណី រំលោភដោយ បុគ្គលមានអំណាច | ៤២ ករណី រំលោភដោយ បុគ្គលមានអំណាច |

[11] របាយការណ៍ស្តីពីស្ថានភាពវិវាទដីធ្លីឆ្នាំ២០២១ https://www.adhoccambodia.org/km/khmer-%E1%9E%9A%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%8E%E1%9F%8D%E1%9E%9F%E1%9F%92%E1%9E%8F%E1%9E%B8%E1%9E%96%E1%9E%B8%E1%9E%9F%E1%9F%92%E1%9E%90%E1%9E%B6%E1%9E%93%E1%9E%97/

## ២.១. រំលោភដោយបុគ្គលមានអំណាច

ឆ្នាំ២០២២ ករណីវិវាទដីធ្លី ដែលបានកើតឡើងដោយបុគ្គលមានអំណាចរំលោភបំពានមានចំនួន ៥០%( ៤២ករណី )នៃករណីសរុបចំនួន៨៤បានរកឃើញ។ករណីនេះប៉ះពាល់ដីទំហំ៦៣៨,៩៣២ហិកតា និងមានជនរងគ្រោះផ្ទាល់ចំនួន១,៣២៦គ្រួសារ ស្មើនឹង៦,០៦២នាក់ មានស្ត្រី២,៩២១នាក់ និងជនជាតិដើមភាគតិច១៧នាក់។

ករណីទាំងនោះ ប្រជាពលរដ្ឋសហគមន៍ បានព្យាយាមស្វែងរកដំណោះស្រាយ ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលក្នុងនោះ ០២ករណីបិទ ដោយជនរងគ្រោះទទួលបានដី និងសំណង ០៣ករណីកំពុងដំណើរការនៅតុលាការ ១២ករណីកំពុងរកដំណោះស្រាយនៅថ្នាក់ខេត្ត-ថ្នាក់ស្រុក និង២៣ករណីមិនទាន់មានដំណោះស្រាយ នៅតាមស្ថាប័នណានៅឡើយទេ ហើយលើសពីនោះទៀត តំណាងប្រជាសហគមន៍មួយចំនួន ត្រូវបានទទួលរងនូវការប្ដឹងចោទប្រកាន់ និងតុលាការកោះហៅចូលបំភ្លឺ ពីបទចូលកាន់កាប់ដោយហឹង្សាធ្វើឲ្យប៉ះពាល់ដល់កម្មសិទ្ធិឯកជន ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស បរិហាកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានបទឧក្រិដ្ឋជាអាទិ៍។

- **ទីតាំងភូមិសាស្ត្រនៃវិវាទ៖** ករណីទាំងនោះ បានកើតឡើងនៅក្នុង ខេត្តចំនួន១០ដូចជា៖ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តសៀមរាប ខេត្តស្ទឹងត្រែង និងខេត្តឧត្តរមានជ័យ។ បុគ្គលមានអំណាចដែលបានប្រើឥទ្ធិពលរបស់ខ្លួន ក្នុងវិវាទដីធ្លីមានដូចជា ឧត្តមសេនីយ៍ក្រសួងមហាផ្ទៃ ទីប្រឹក្សាអ្នកមានអំណាច នាយរងកងរាជអាវុធហត្ថខេត្ត នគរបាលព្រំដែន ក្រុមប្រឹក្សាស្រុក ស្មៀនឃុំ រដ្ឋបាលព្រៃឈើ ក្រុមប្រឹក្សាខេត្ត និងមន្ត្រីយោធាជាដើម។
- **រូបភាពដែលបុគ្គលមានអំណាចប្រើក្នុងវិវាទដីធ្លីមានដូចជា៖**
    - ប្រើគ្រឿងចក្រឈូសឆាយដីព្រៃរបស់ប្រជាពលរដ្ឋ ដីមានផលដំណាំ ដែលបាននឹងកំពុងអាស្រ័យផលជាច្រើនឆ្នាំកន្លងមកហើយ។
    - ជួលប្រជាសហគមន៍ផង និងរៀបចំក្រុមមនុស្សជាប្រព័ន្ធផង ឲ្យមានការកាប់រានសំអាតព្រៃកោងកាង ព្រៃលិចទឹកក្នុងតំបន់ការពារធម្មជាតិ។
    - តាមរយៈអាជ្ញាធរមូលដ្ឋាន គម្រាមឲ្យសហគមន៍ ទទួលយកដំណោះស្រាយ ដោយប្រើពាក្យថា៖ បើមិនទទួលយកលុយតាមការកំណត់នោះទេ ដីនោះក៏គង់តែគេយកទទេដែរ ព្រោះគេបានរត់ការឆ្វៀលដីចេញពីដីរដ្ឋ និងធ្វើប្លង់កម្មសិទ្ធិដីក្នុងតំបន់នោះរួចហើយ ហើយបើចង់ប្ដឹងប្រយ័ត្នមានទោសកាន់តែធ្ងន់។

- ជួលប្រជាពលរដ្ឋកាប់រានដីបំផ្លាញព្រៃស្មាច់ និងដើមអាកាស្យាលិចទឹក បន្ទាប់មកប្រមូលទិញក្នុងតម្លៃថោកៗ ហើយយកទៅលក់ឲ្យឈ្មួញ ឬអ្នកមានប្រាក់ (កាប់បានទំហំដីប៉ុន្មានវាស់គិតលុយប៉ុណ្ណោះ ដោយមិនមានការទទួលស្គាល់ពីអាជ្ញាធរឡើយ)។
- ប្រើអំណាចជាមន្ត្រីដើម្បីរត់ការធ្វើសំបុត្រផ្ទេរកម្មសិទ្ធិ។
- ហាមឃាត់ មិនឲ្យប្រជាសហគមន៍ អាស្រ័យផលលើដី ព្រមទាំងប្តឹងចោទប្រកាន់ទៅតុលាការ។
- ដាក់ពាក្យបណ្តឹងទៅតុលាការ និងហាមឃាត់មិនឲ្យអាស្រ័យផល ដាំដំណាំនៅលើដីរបស់ខ្លួន។
- គម្រាមកំហែង ឲ្យផ្តិតស្នាមមេដៃលើដំណោះស្រាយដីធ្លី បន្ទាប់មកមេឃុំចេញលិខិតផ្ទេរសិទ្ធិកាន់កាប់លើដីដែលកំពុងមានវិវាទ។
- មន្ត្រីបរិស្ថានគំរាមកំហែង បន្ទាប់ពីតំណាងសហគមន៍ ផុសក្នុងបណ្តាញសង្គមហ្វេសប៊ុករឿងការប្រើអាអិចឈូសឆាយក្នុងតំបន់ព្រៃឡង់។
- មន្ត្រីបរិស្ថាន ហាមមិនឲ្យតំណាងសហគមន៍ថតសកម្មភាពឈូសឆាយព្រៃឡង់ ព្រមទាំងដកយកទូរស័ព្ទលុបរូបថតចោល។
- ដកហូតដីដោយសំអាងថា ជាដីរបស់សហគមន៍ ដើម្បីយកមកប្រគល់ឲ្យបុគ្គលម្នាក់ទៀតកាន់កាប់ និងដាំដុះអាស្រ័យផល ដោយគ្មានសំណងជួសជុល ព្រមទាំងគំរាមចាប់ដាក់គុកប្រសិនបើមិនព្រមប្រគល់ដីនោះ។
- មេភូមិ ស្មៀន មេឃុំ បានកាប់រានរំលោភយកដីព្រៃលិចទឹក ដីព្រៃជំនឿអ្នកតាយកមកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន។
- អភិបាលរងស្រុកដឹកនាំកម្លាំង រារាំងហាមឃាត់ មិនឲ្យប្រជាសហគមន៍សាងសង់ផ្ទះនៅលើដីដែលបានកាន់កាប់ និងអាស្រ័យផលជាច្រើនឆ្នាំ ព្រមទាំងបំផ្លាញផលដំណាំជាច្រើន។

## ២.២. រំលោភដោយអ្នកមានទ្រព្យ

យោងតាមការអង្កេតឆ្នាំ២០២២ ករណីករណីវិវាទដីធ្លី ដែលមានអត្រាខ្ពស់ទី២ បន្ទាប់ពីការរំលោភដោយបុគ្គលមានអំណាចគឺ ករណីវិវាទដីធ្លីដែលបណ្តាលមកពីអ្នកមានទ្រព្យធនរំលោភបំពាន មានចំនួន ១៦ករណី ប៉ះពាល់ដីទំហំ ៧៩២.១៧ហិកតា និងមានជនរងគ្រោះផ្ទាល់ចំនួន ៨២៧គ្រួសារ ស្មើនឹង ១៤,៨១៩នាក់ មានស្ត្រី១,៥៥៣នាក់ និងជនជាតិដើមភាគតិច៥០៧នាក់ ដែលក្នុងនោះ ០១ករណីកំពុងដំណើរការនីតិវិធីនៅតុលាការ ០៤ករណីកំពុងរកដំណោះស្រាយនៅថ្នាក់ស្រុក-ឃុំ/សង្កាត់ ហើយ១១

ករណីទៀតមិនទាន់មានដំណោះស្រាយ ពីស្ថាប័នណានៅឡើយទេ ។ ម៉្យាងវិញទៀតតំណាងប្រជាសហគមន៍មួយចំនួន ត្រូវបានទទួលរងនូវការប្តឹងចោទប្រកាន់ និងតុលាការកោះហៅចូលបំភ្លឺពីបទចូលកាន់កាប់ ដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់កម្មសិទ្ធិឯកជនធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសបរិហាកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានបទឧក្រិដ្ឋជាអាទិ៍។

- **ទីតាំងភូមិសាស្រ្តនៃវិវាទ៖** ករណីទាំងនោះ បានកើតឡើងនៅក្នុងខេត្តចំនួន ០៧ ដូចជា៖ ខេត្តកោះកុងខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី ខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង។

រូបភាពដែលបុគ្គលមានទ្រព្យប្រើក្នុងវិវាទដីធ្លីមានដូចជា៖ តំណាងក្រុមហ៊ុន ប្រើគ្រាក់ទ័រគ្រឿងចក្រឈូសឆាយដីផលដំណាំ ព្រមទាំងគំរាមប្តឹងប្រជាសហគមន៍ទៅតុលាការ បោះបង្គោលបិទផ្លូវមិនឲ្យប្រជាសហគមន៍ធ្វើដំណើរទៅធ្វើស្រែចំការ ក្នុងគោលបំណងយកដីទៅលក់បន្ត។

## ២.៣. ការបណ្តេញចេញ

ឆ្នាំ២០២២ ករណីវិវាទដីធ្លីរហូតដល់ មានការបណ្តេញចេញ បានរកឃើញចំនួន១០ករណី ប៉ះពាល់ដីរបស់ប្រជាពលរដ្ឋចំនួន៦,៥៦១.០៨៨ហិកតា និងជនរងគ្រោះផ្ទាល់ ចំនួន៤,១០០គ្រួសារស្មើនឹងចំនួន១២,៦៥៦នាក់ ស្ត្រី៧,០៥៧នាក់ ដែលក្នុងនោះមាន០៤ករណី កំពុងដំណើរការនីតិវិធីរបស់អាជ្ញាធរថ្នាក់ជាតិ និងមាន០២ករណី ស្ថិតនៅដំណាក់កាលរងចាំការដោះស្រាយរបស់អាជ្ញាធរថ្នាក់ខេត្ត មាន០១ករណីកំពុងដំណើរការនីតិវិធីតុលាការ និង០៣ករណីទៀត មិនទាន់មានដំណោះស្រាយនៅឡើយ។ ករណីទាំងនោះកើតឡើង នៅក្នុងខេត្ត-ក្រុងចំនួន០៣គឺ៖ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង និងរាជធានីភ្នំពេញ។

ករណីវិវាទដីធ្លីដែលបង្ខំឲ្យចាកចេញទៅរស់នៅកន្លែងផ្សេង តាមការកំណត់របស់អាជ្ញាធរក្រោមរូបភាពដោះដូរដី និងផ្តល់ប្រាក់ឧបត្ថមមួយចំនួន ដើម្បីយកដីនោះមកធ្វើការអភិវឌ្ឍន៍ និង-ឬអភិរក្សបេតិកភណ្ឌ។ នៅអំឡុងខែតុលាឆ្នាំ២០២២ មានករណីកើតឡើងនៅភូមិ-ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលប៉ះពាល់ដល់១,៩០០គ្រួសារ ទំហំដី៥០០០ហិកតា ដែលនៅពេលនោះ រដ្ឋាភិបាលបានកំណត់នូវវិធានការបួនចំណុច ប្រសិនបើប្រជាពលរដ្ឋនៅទីនោះមិនយល់ព្រមចាកចេញគឺ៖

- មិនផ្តល់កម្មសិទ្ធិដីធ្លី
- មិនផ្តល់សេវាអគ្គីសនី
- មិនផ្តល់សេវាទឹកស្អាត
- មិនផ្តល់សេវាសាធារណៈក្នុងការបញ្ជាក់ឯកសារពាក់ព័ន្ធកម្ចីពីធនាគារម៉ៃក្រូហិរញ្ញវត្ថុ

ផែនការនេះ ត្រូវបានផ្អាកក្រោយពីមានការតវ៉ាយ៉ាងខ្លាំង ពីប្រជាពលរដ្ឋរស់នៅតំបន់នោះ ដែលមិនព្រមចាកចេញទៅរស់នៅកន្លែងថ្មី ភូមិធម្មជាតិរុនតាឯក។

## ២.៤. សម្បទានដីសេដ្ឋកិច្ច

វិវាទដីធ្លីដែលបានកើតឡើង ដោយសារដីសម្បទានសេដ្ឋកិច្ច មាន៦ករណី ប៉ះពាល់ដីចំនួន ១,៩៥២.៨៧ហិកតា និងជនរងគ្រោះផ្ទាល់ចំនួន៣៤៣គ្រួសារស្មើនិង១,៤០២នាក់ ស្ត្រី៦៧៥នាក់ ក្នុងនោះមានជនជាតិដើមភាគតិចចំនួន២៩១គ្រួសារ (១,១៦២នាក់)។ ០១ករណីក្រសួងដែនដី បង្គាប់ឲ្យអភិបាលខេត្តចុះដោះស្រាយ០៣ករណី អាជ្ញាធរថ្នាក់ខេត្តកំពុងដោះស្រាយ និង០២ករណី មិនទាន់មានដំណោះស្រាយនៅឡើយទេ។ ករណីទាំងនោះ កើតឡើងនៅក្នុងខេត្តដូចជា៖ ខេត្តព្រះវិហារ ខេត្តពោធិសាត់ ខេត្តព្រះសីហនុ និងខេត្តកំពង់ធំ។

ដីសម្បទានសេដ្ឋកិច្ចដែលនាំឲ្យក្រុមហ៊ុនប្រើគ្រឿងចក្រឈូសឆាយដី និងផលដំណាំប្រជាពលរដ្ឋ ហើយថែមទាំងប្ដឹងប្រជាពលរដ្ឋទៅអាជ្ញាធរស្រុក-តុលាការ បន្ទាប់ពីប្រជាពលរដ្ឋចុះមកហាមឃាត់មិនឲ្យមានការឈូសឆាយដីរបស់ពួកគេ។ អាជ្ញាធរឃុំបានហៅប្រជាពលរដ្ឋពាក់ព័ន្ធធ្វើកិច្ចសន្យាផ្ដិតស្នាមមេដៃឈប់ចូលកាន់កាប់ដីទំនាស់ បើមិនដូច្នោះទេមេភូមិ-មេឃុំគម្រាមចាប់ខ្លួនដាក់គុក ហើយក៏មានតំណាងប្រជាសហគមន៍មួយចំនួនត្រូវបានចាប់ឃុំខ្លួន បន្ទាប់ពីមានពាក្យបណ្ដឹងពីក្រុមហ៊ុន។

# អនុសាសន៍ផ្នែកសិទ្ធិដីធ្លី

១. បញ្ឈប់ការប្រើកងកម្លាំងប្រដាប់អាវុធទៅបង្ក្រាបអ្នកតវ៉ាទាមទារដោយសន្តិវិធី ដើម្បីការពារភាគីក្រុមហ៊ុន និងបុគ្គលមានទ្រព្យ-មានអំណាច។

២. បញ្ឈប់ការប្តឹងប្រជាពលរដ្ឋពីបទព្រហ្មទណ្ឌទៅតុលាការ ដោយសាររឿងវិវាទដីធ្លី ឬតុលាការត្រូវបង្អង់រឿងព្រហ្មទណ្ឌ ដោយងាកទៅចំណាត់ការដោះស្រាយរឿងវិវាទរដ្ឋប្បវេណីជាមុនសិន។

៣. ពិនិត្យការអនុវត្តន៍ អនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងបញ្ហាវិវាទដីធ្លីប្រកប ដោយប្រសិទ្ធិភាពខ្ពស់។

៤. ក្រសួងពាក់ព័ន្ធ តុលាការ គណៈកម្មការដោះស្រាយវិវាទដីធ្លី ពន្លឿន និងពង្រឹងការដោះស្រាយបញ្ចប់វិវាទដីធ្លីដែលនៅកកស្ទះឲ្យបានឆាប់រហ័ស មានតម្លាភាព យុត្តិធម៌ និងមិនលំអៀង។

៥. ពង្រឹង និងពិនិត្យវាយតំលៃលើសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីពាក់ព័ន្ធ និងផ្តល់សិទ្ធិអំណាចដល់ពួកគាត់ក្នុងការផ្តល់យុត្តិធម៌ដល់គូភាគី។

៦. ត្រួតពិនិត្យវាយតម្លៃលើការអនុវត្តតួនាទីរបស់មន្ត្រីពាក់ព័ន្ធក្នុងការដោះស្រាយវិវាទដីធ្លី ដាក់ពិន័យ និងអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

# ផ្នែកទី៣៖ ផ្នែកសិទ្ធិស្ត្រី និងកុមារ




នៅក្នុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញ មានករណីរំលោភបំពាន់លើសិទ្ធិស្ត្រី និងកុមារ ចំនួន២៨៨ករណី កើនឡើង៦៤ករណី ធៀបនឹងរបកគំហើញឆ្នាំ២០២១ មានត្រឹមតែចំនួន ២២៤ករណីប៉ុណ្ណោះ។ ករណីទាំងនោះរួមមាន៖ ការជួញដូរផ្លូវភេទចំនួន៦១ករណី(បង្ខំរៀបការទៅប្រទេសចិន ៥៧ករណី)ការជួញដូរកំលាំងពលកម្មចំនួន១៧ករណី(បំរើការក្នុងផ្ទះនៅប្រទេសម៉ាឡេស៊ីចំនួន១០ករណី) អំពើហិង្សាក្នុងគ្រួសារចំនួន៧៨ករណី (ហឹង្សារហូតដល់ស្លាប់ចំនួន២២ករណី) និងរំលោភសេពសន្ថវៈចំនួន១៣២ករណី(រំលោភសម្លាប់ចំនួន០៦ករណី)។

## តារាងទិន្នន័យករណី

| ផ្នែកសិទ្ធិស្ត្រី និងកុមារ | ឆ្នាំ ២០២០ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ |
|---|---|---|---|
| ចំនួនករណី | ៣០៨ | ២២៤ | ២៨៨ |
| ចំនួនជនរងគ្រោះ | ៣៣១ | ២៥៦ | ៣១៥ |
| ចំនួនជនរងគ្រោះករណីហិង្សាក្នុងគ្រួសារស្លាប់ | ១៥ | ០៧ | ២២ |
| ចំនួនជនរងគ្រោះករណីរំលោភសម្លាប់ | ០៣ | ០៤ | ០៦ |

## ៣.១. ករណីជួញដូរផ្លូវភេទ




អំឡុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញមានករណីជួញដូរផ្លូវភេទចំនួន ៦១ករណី មានជនរងគ្រោះចំនួន៦៣នាក់ ជាស្ត្រីទាំងអស់។

នៅក្នុងចំណោម៦១ករណី មាន៤៣ករណី ដែលជនរងគ្រោះកំពុងនៅតែមានវត្តមានក្នុងប្រទេសចិន រង់ចាំការជួយអន្តរាគមន៍ ដើម្បីបានវិលត្រឡប់មកមាតុប្រទេសវិញ ហើយ២ករណីជនរងគ្រោះកំពុងតែមានផ្ទៃពោះ។ ព្រមទាំងមាន៩ករណី បាត់ដំណឹងគ្មានព័ត៌មាន ក្រុមគ្រួសារមិនអាចទំនាក់ទំនងបាន។ មានតែ៣ករណីប៉ុណ្ណោះ ដែលជនប្រព្រឹត្តត្រូវបានចាប់ខ្លួន ករណីខ្លះមិនស្គាល់អត្តសញ្ញាណជនប្រព្រឹត្ត និងករណីខ្លះទៀត ជនប្រព្រឹត្តនៅមានសេរីភាពជាធម្មតា។ សមាគមអាដហុក បានជួយអន្តរាគមន៍ សម្របសម្រួលក្រុមគ្រួសារជនរងគ្រោះ ដាក់ពាក្យបណ្ដឹងទៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងទំនាក់ទំនងអន្តរជាតិចំនួន ២១ករណី។

- **មូលហេតុចម្បងគឺការចាញ់បោកការលួងលោមរបស់មេខ្យល់ ហើយដែលភាគច្រើនកើតចេញពីៈ** សង្គមសំភារៈនិយម ការចាញ់បោកសង្សា និងមិត្តភក្តិជិតដិត ការលែងលះ និងគ្មានក្ដីសុខក្នុងគ្រួសារ ការរៀនសូត្របានតិចអស់សង្ឃឹមក្នុងជីវិត ភាពអត់ការងារធ្វើ គ្រួសារក្រីក្រ មានអំពើហិង្សាក្នុងគ្រួសារ ជំពាក់បំណុលច្រើនដោះស្រាយអត់ចេញ ជឿទុកចិត្តពាក្យឃោសនាអូសទាញរបស់ជនឆបោក មេខ្យល់ និងក្រុមហ៊ុនតាមបណ្ដាញសង្គម មានការរើសអើងភេទក្នុងគ្រួសារ និងសហគមន៍ ចង់បានប្រាក់ខែច្រើនដើម្បីជួយគ្រួសាររួចផុតពីភាពក្រីក្រ គេចពីការតាមចាប់ខ្លួន(រឿងនយោបាយ) បាត់បង់ដីធ្លី ផ្ទះសំបែង ដោយសារករណីរំលោភពីអ្នកមានអំណាច ហើយពុំមានដំណោះស្រាយពីរដ្ឋ ជាពិសេសគ្មានប្រព័ន្ធទឹកសំរាប់ប្រើប្រាស់គ្រប់គ្រាន់ ដើម្បីធ្វើកសិកម្ម។

- **បញ្ហាជនរងគ្រោះបានជួបប្រទះនៅក្រៅប្រទេសមានដូចជា៖**
    - រងអំពើហិង្សាក្នុងគ្រួសារនៅប្រទេសដែលកំពុងរងគ្រោះ (រងអំពើហិង្សាផ្ទាល់ពីប្ដី និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចកម្លាំងពលកម្មពីថៅកែ រឺ ក្រុមហ៊ុន)
    - មិនទទួលបានបានសិទ្ធិជ្រកកោនស្របច្បាប់ ពីប្រទេសដែលកំពុងរងគ្រោះ
    - បាត់បង់កិត្តិយស ក្តីសុខផ្ទាល់ខ្លួន និងមិនអាចទាក់ទងគ្រួសារបាន
    - ចង់ត្រឡប់មកស្រុកកំណើតវិញ មិនមានមធ្យោបាយ ហើយត្រូវរងគ្រោះដោយលក់បន្តដូចសត្វ។
    - លិខិតឆ្លងដែន និងឯកសារស្របច្បាប់ផ្ទាល់ខ្លួន ត្រូវបានមេខ្យល់ដកទុក
    - បង្ខំលក់បន្ត និងបង្ខំរួមភេទ ព្រមទាំងបង្កើតកូនឱ្យគេដូចបំណងដែលគេចង់បាន
    - ជនរងគ្រោះខ្លាច អត់ហ៊ានរត់ចេញពីកន្លែងដែលគាត់រស់នៅ
    - អត់មានលុយ និងមធ្យោបាយជួយខ្លួនឯងបាន
    - ខ្លាចការគំរាមពីមេខ្យល់ និងប្តីចិន

## ៣.២. ករណីជួញដូរកម្លាំងពលកម្ម




អំឡុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញថា មានការជួញដូរកម្លាំងពលកម្មចំនួន១៧ករណី ដែលមានជនរងគ្រោះចំនួន ២៣នាក់ ស្រី១៧នាក់ ដែលភាគច្រើនជនរងគ្រោះរស់នៅក្នុងខេត្តកំពង់ឆ្នាំង កំពត ព្រះវិហារ ព្រៃវែង ព្រះសីហនុ ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ។ ករណីនេះ ជនរងគ្រោះដែលពួកគាត់ទៅរកការងារធ្វើ ហើយទទួល

រងគ្រោះនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសថៃ ប្រទេសអារ៉ាប់ប៊ីសាវអូឌីត និងក្នុងប្រទេសកម្ពុជា ជាប្រទេសកំណើតរបស់ខ្លួនផងដែរ។

ជាទូទៅជនរងគ្រោះទៅធ្វើការក្នុងវិស័យមួយចំនួនដូចជា៖ វិស័យកសិកម្ម សំណង់ នេសាទ ការងារតាមផ្ទះ រោងចក្រ អនាម័យ លក់បាយ ទទួលភ្ញៀវ និងរើសអេតចាយ។ ហើយស្ថានភាពរំលោភបំពានដែលពួកគាត់ជួបប្រទះភាគច្រើន គឺបង្ខំឲ្យធ្វើការងារលើសម៉ោង មិនបើកប្រាក់ខែ ឬបើកមិនគ្រប់ មិនឲ្យញ៉ាំគ្រប់គ្រាន់ និងប្រើប្រាស់អំពើហិង្សាជាដើម។ ក្នុងចំណោមនេះ មានជនរងគ្រោះ ២នាក់ ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរថៃ និងមាន ៧ករណី កំពុងតែបាត់ដំណឹងនៅក្រៅប្រទេសនៅឡើយ។

ករណីទាំងអស់នេះ មិនមានជនប្រព្រឹត្តណាម្នាក់ត្រូវបានចាប់ខ្លួនមកផ្តន្ទាទោសឡើយ។ មូលហេតុដែលនាំឲ្យពួកគាត់ចាញ់បោកមេខ្យល់ ដោយសារតែភាពអត់ការងារធ្វើ គ្រួសារក្រីក្រ មានអំពើហិង្សាក្នុងគ្រួសារ និងជំពាក់បំណុលច្រើនដោះស្រាយអត់ចេញ ជឿទុកចិត្តពាក្យឃោសនាអូសទាញរបស់ជនឆបោក មេខ្យល់ និងក្រុមហ៊ុនតាមបណ្តាញសង្គម មានការរើសអើងភេទក្នុងគ្រួសារ និងសហគមន៍ ចង់មានប្រាក់ខែច្រើន ដើម្បីជួយគ្រួសារ រួចផុតពីភាពក្រីក្រ គេចវេសពីការតាមចាប់ខ្លួន(រឿងនយោបាយ) បាត់បង់ដីធ្លី ផ្ទះសំបែង ដោយសារករណីរំលោភពីអ្នកមានអំណាច ហើយពុំមានដំណោះស្រាយ ជាពិសេសគ្មានប្រព័ន្ធទឹកសំរាប់ប្រើប្រាស់គ្រប់គ្រាន់ និងសំរាប់ធ្វើកសិកម្ម។

## ៣.៣. ករណីហឹង្សាក្នុងគ្រួសារ



អំឡុងឆ្នាំ២០២២ សមាគមអាហុកបានរកឃើញមាន ករណីហិង្សាក្នុងគ្រួសារចំនួន៧៨ករណី មានជនរងគ្រោះចំនួន៨៧នាក់ ក្នុងនោះមានបុរស៦នាក់។

បើតាមការវាយតម្លៃបានបង្ហាញថា៖ ខេត្តកំពង់ស្ពឺ ឈរលំដាប់លេខ១ ដែលមានករណីកើតឡើងចំនួន២៣ករណី លំដាប់លេខ២ខេត្តសៀមរាប មានចំនួន១២ករណី និងលំដាប់លេខ៣ ខេត្តកំពង់ធំមានចំនួន៧ករណី។ ហើយករណីទាំងនេះ មិនរាប់បញ្ចូលករណីដែលសមាគមអាដហុកមិនបានទទួលពាក្យសុំអន្តរាគមន៍នោះទេ។

២៤ករណីគឺជាហិង្សាធ្ងន់ធ្ងររហូតដល់ជនរងគ្រោះស្លាប់បាត់បង់ជីវិតដែលក្នុងនោះមាន៖

- **១៤ករណី៖** ជនប្រព្រឹត្តជាប្តី ប្រើកាំបិត ពូថៅ ញញួរ និងខ្សែរឹត-ក-សម្លាប់ប្រពន្ធ មូលហេតុភាគច្រើនបណ្តាល មកពីបញ្ហាប្រច័ណ្ឌ ទំនាស់ពាក្យសំដី សេពគ្រឿងស្រវឹង និងប្រើប្រាស់គ្រឿងញៀន។ ករណីទាំងនោះ មុនឈានដល់ហិង្សារហូតដល់ស្លាប់ ដោយសារតែមានជម្លោះរ៉ាំរ៉ៃ និងបង្កហិង្សាជាញឹកញាប់ក្នុងគ្រួសារ រហូតមាន៣គ្រួសារក្នុងចំណោមនេះ ត្រូវបានប៉ូលីសចាប់ដាក់ពន្ធនាគារម្តងរួចហើយ ដោយសារតែការបង្ករបួសស្នាមលើសមាជិកគ្រួសារមានដូចជា កូន និងប្រពន្ធ ជាដើម។

- **០១ករណី៖** ជនប្រព្រឹត្តជាប្រពន្ធ បានវាយសម្លាប់ប្តីខ្លួនឯង ហើយការវាយសម្លាប់នេះទៀត គឺមូលហេតុដោយសារតែ ប្តីតែងតែផឹកស្រាហើយបង្កជម្លោះ និងវៃប្រពន្ធ អត់ទ្រាំលែងបាន ទើបឈានដល់ការសម្លាប់នេះ ។ មុនពេលកើតហេតុ បុរសជាប្តី បានផឹកស្រាស្រវឹង ហើយយកផ្លែដូងខ្ចីគប់ក្បាលប្រពន្ធពីរផ្លែដូង ហើយរត់ដេញវៃប្រពន្ធដល់ក្រៅផ្ទះ ប្រពន្ធទ្រាំលែងបាន ក៏ទាញដំបងឬស្សីវៃតបវិញ រហូតដល់ស្លាប់។

- **០៥ករណី៖** ជនប្រព្រឹត្តជាឪពុកបង្កើត មានកំហឹងវៃសម្លាប់កូនខ្លួនឯងបង្កើត (ដែលជាក្មេងទើបមានអាយុ ០៨ខែ-១៣ខែ) ដោយច្របាច់-ក-សម្លាប់ ប្រើដំបងឈើវាយលើរូបរាងកាយ និងយកភ្លើងបារីអុចលើខ្លួនប្រាណកូន និងប្រើកៅអីជ័រវាយរហូតដល់ស្លាប់។ មូលហេតុនៃការសម្លាប់គឺដោយសារតែ រឿងប្រច័ណ្ឌប្រពន្ធរបស់ខ្លួនថា មានសាហាយស្មន់ ជាមួយអ្នកដទៃនៅក្នុងភូមិជាមួយគ្នា ហើយចោទថា កូនក្មេងដែលបានវាយសម្លាប់នោះ ប្រពន្ធរបស់ខ្លួនមានមួយសាហាយទៅវិញ។ ករណីទាំង០៥នេះ បានកើតនៅខេត្តកំពង់ស្ពឺ ០២ករណី (ក្មេងមានអាយុ០៥ខែ និង១២ខែ) ខេត្តកំពង់ឆ្នាំង ០១ករណី (ក្មេងមានអាយុ១៣ខែ) ខេត្តកំពង់ធំ ០១ករណី (ក្មេងមានអាយុ០៨ខែ) និងនៅខេត្តបន្ទាយមានជ័យ០១ករណី (ក្មេងមានអាយុ១៣ខែ)។

- **០៤ករណី៖** ជនប្រព្រឹត្តជាកូន ជាចៅ និងជាឪពុកមា បានសម្លាប់ឪពុក យាយ និងក្មួយ ដែលជាសាច់ញាតិរបស់ខ្លួន ដោយសារតែមូលហេតុមានសតិមិនប្រក្រតី ព្រោះតែផឹកស្រា និងប្រើប្រាស់គ្រឿងញៀន។

៤៨ករណីក្នុងចំណោម៧៨ករណី ជនប្រព្រឹត្តត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធី ច្បាប់។ មានតែ០៥ករណីប៉ុណ្ណោះ ដែលជនប្រព្រឹត្តបានរត់គេចខ្លួន ៣ករណីទៀត ជនប្រព្រឹត្តបានស្លាប់ និង២២ករណី ជនប្រព្រឹត្តកំពុងតែមានសេរីភាពជាធម្មតា។

## ៣.៤. ករណីរំលោភសេពសន្ថវៈ




អំឡុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញ មានករណីរំលោភសេពសន្ថវៈមានចំនួន ១៣២ករណី មានជនរងគ្រោះសរុបចំនួន ១៤២នាក់ ដែលក្នុងនោះមាន ជនរងគ្រោះជាព្រះសង្ឃ (លោកនេន) ចំនួន០២អង្គ ដែលមានព្រះជន្មាយុ១៤-១៥វស្សា ដោយជនប្រព្រឹត្តជាព្រះសង្ឃ (គ្រូសូត្រស្តាំ) នៅវត្តទំនប់តាកួន ស្ថិតនៅក្នុងភូមិទំនប់តាកួន ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង ដែលនៅពេលនោះ ជនប្រព្រឹត្តបានប្រើ កាំបិទ ពូថៅ ដើម្បីគម្រាមសម្លាប់ជនរងគ្រោះ។

ក្នុងចំណោម១៣២ករណីមាន០៦ករណី ដែលមានជនរងគ្រោះត្រូវបានជនប្រព្រឹត្តរំលោភ ហើយសម្លាប់ចោល ដែលបណ្តាលមកពីមូលហេតុធំៗចំនួន ៣គឺៈ

១. ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងៈ តាមការសង្កេតស្ទើរគ្រប់ករណីនៅមុនពេលចាប់រំលោភសេពសន្ថវៈ ជនប្រព្រឹត្តមានប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន ព្រោះតែឥទ្ធិពលនេះហើយដែលជាមូលហេតុជម្រុញឲ្យជនប្រព្រឹត្តិហ៊ានប្រព្រឹត្តល្មើសច្បាប់ និងសីលធម៌សង្គម។

២. អគុល្យភាពនៃអំណាចរវាងបុរស និងស្ត្រីៈ បុរសទោះចាស់ ឬក្មេងនៅតែមានគំនិតមើលងាយស្ត្រី និងកុមារីទើបហ៊ានចាប់រំលោភព្រោះតែអាងកម្លាំងកាយ បញ្ហាសេដ្ឋកិច្ច និងអំណាចនៃការគម្រាមកំហែង។

៣. និទណ្ឌភាពៈ ជនប្រព្រឹត្តធ្លាប់ប្រព្រឹត្តបទល្មើសកន្លងមក ហើយរួចខ្លួន ដោយសារអំពើពុករលួយ ក៏ដូចជាធ្វើតាមទម្លាប់ ឬទស្សនៈសង្គម ដោយធ្វើការសម្របសម្រួលផ្ទះនឹងផ្តល់លុយសំណងដើម្បីបញ្ចប់រឿង ឬក៏រៀបការដើម្បីលាក់បាំងភាពអាម៉ាស់របស់ជនរងគ្រោះ។ ម្យ៉ាងទៀតដោយសារតែជនរងគ្រោះមិនមាន

ជំនឿលើប្រព័ន្ធតុលាការ ជាពិសេសបើទោះជាមានសំណងតាមប្រព័ន្ធតុលាការហើយក៏ដោយ ក៏ភាគច្រើនគឺមានតែសំណងនៅលើក្រដាសប៉ុណ្ណោះ កម្រនឹងទទួលបានសំណងជាលុយដល់ដៃជនរងគ្រោះ ឬគ្រួសារជនរងគ្រោះណាស់។

## ករណីរំលោភសេពសន្ថវៈមានជនរងគ្រោះអាយុចន្លោះ៖

- ៣ឆ្នាំ ដល់ ១០ឆ្នាំ ករណី មានចំនួន ៣០នាក់
- ១១ឆ្នាំ ដល់ ១៧ឆ្នាំ ករណី មានចំនួន ៧១នាក់
- ១៨ឆ្នាំ ដល់ ៦៣ឆ្នាំ ករណី មានចំនួន ១៤នាក់

**ជនប្រព្រឹត្តគឺជា៖**

| ជនប្រព្រឹត្តជា | ចំនួនជនរងគ្រោះ | ជនប្រព្រឹត្តជា | ចំនួនជនរងគ្រោះ |
|---|---|---|---|
| អ្នកជិតខាង | ៤៧នាក់ (៣៦%) | អ្នកស្គាល់គ្នា | ១៩នាក់(១៤%) |
| ឪពុកមា | ១៧នាក់ (១៣%) | ឪពុកចុង | ១៥នាក់ (១១%) |
| ឪពុកបង្កើត | ១១នាក់ | អ្នកមិនស្គាល់គ្នា | ០៥នាក់ |
| បងប្រុស | ០៤នាក់ | តាមបណ្តាញសង្គម | ០៤នាក់ |
| ជីតា | ០៣នាក់ | បងថ្លៃ | ០៣នាក់ |
| បងប្អូនជីដូនមួយ | ០៣នាក់ | មិត្តប្រុស | ០២នាក់ |
| មិត្តភក្តិ | ០១នាក់ | កូនប្រុស | ០១នាក់ |
| ប្រធាន | ០១នាក់ | | |

# អនុសាសន៍ផ្នែកសិទ្ធិស្ត្រី និងកុមារ

## ករណីរំលោភសេពសន្ថវៈ និងហិង្សាក្នុងគ្រួសារ៖

១. ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវពង្រឹងការអនុវត្តច្បាប់ ដាក់ទោសទណ្ឌដល់ជនល្មើស ដើម្បីបញ្ចប់អំពើនិទណ្ឌភាព។

២. ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវពន្លឿននីតិវិធី និងធានាថា សំណងរដ្ឋប្បវេណីបានដល់ដៃជនរងគ្រោះ ជៀសវាងទទួលបានតែនៅលើសេចក្ដីសំរេច (សាលក្រម-សាលដីកា) ដែលជាកត្តានាំឲ្យជនរងគ្រោះស្វែងរកវិធីសម្របសម្រួលក្រៅប្រព័ន្ធតុលាការដើម្បីបញ្ចប់រឿង។

៣. ក្រសួងមហាផ្ទៃ ត្រូវពង្រឹងយន្តការ ទប់ស្កាត់លំហូរនៃគ្រឿងញៀន និងផ្ដន្ទាទោសឲ្យធ្ងន់ធ្ងរចំពោះជនជួញដូរគ្រឿងញៀន។ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធការបង្ក្រាបបទល្មើសប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា។

៤. ច្បាប់ប្រើប្រាស់គ្រឿងស្រវឹង ត្រូវបានពង្រាងតាំងពីឆ្នាំ២០១៤ ប៉ុន្តែរហូតដល់បច្ចុប្បន្ននៅមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់នៅឡើយ ក្រសួងមហាផ្ទៃ គួរតែពន្លឿននីតិវិធីក្នុងការអនុម័ត ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ។

៥. ក្រសួងព័ត៌មាន និងអាជ្ញាធរដែនដី ត្រូវធ្វើការត្រួតពិនិត្យ និងកាត់បន្ថយការដាក់តាំងស្លាកគ្រឿងស្រវឹងតាមដងផ្លូវ និងទីសាធារណៈ ជាពិសេសការផ្សព្វផ្សាយគ្រឿងស្រវឹងតាមគ្រប់រូបភាព។ ដោយហេតុថា ស្ទើរគ្រប់ករណីមុនបង្កហេតុជនរងគ្រោះ សុទ្ធតែប្រើប្រាស់គ្រឿងស្រវឹង។

៦. ក្រសួងព័ត៌មាន ត្រូវពង្រឹងប្រព័ន្ធត្រួតពិនិត្យគេហទំព័រផ្សព្វផ្សាយរឿងអាសអាភាស តាមអ៊ិនធ័រណេត

៧. ក្រសួងកិច្ចការនារី ត្រូវបង្កើនការផ្សព្វផ្សាយពីសិទ្ធិនារី សមភាពយេនឌ័រ និងច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ឲ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ។

៨. ក្រសួងអប់រំ ត្រូវបង្កើនការផ្សព្វផ្សាយពីវប្បធម៌ខ្មែរនៅតាមសាលារៀន និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ជាពិសេសទាក់ទងនឹងតម្លៃស្ត្រី។ គោលបំណង នៃការអប់រំផ្សព្វផ្សាយ គឺដើម្បីផ្លាស់ប្ដូរអាកាប្បកិរិយា និងទស្សនៈសង្គមមួយចំនួនដែលធ្វើឲ្យគុល្យភាពអំណាចរវាងបុរស និងស្ត្រី។

## ជនរងគ្រោះផ្ទាល់៖

១. ជនរងគ្រោះខ្លួនឯង ក៏ត្រូវតែមានភាពក្លាហានហ៊ាននិយាយ និងស្វែងរកយុត្តិធម៌សំរាប់ខ្លួនឯងចំពោះការរំលោភបំពាននានា ដោយមិនត្រូវអត់ធ្មត់ លាក់បាំង ចំពោះអំពើរំលោភបំពានទាំងឡាយលើខ្លួនឡើយ។

## ករណីជួញដូរផ្លូវភេទ និងជួញកម្លាំងពលកម្ម៖

១. រដ្ឋាភិបាល ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែបង្កើនការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយ ពីស្ថានភាពផលប៉ះពាល់ ពីការចំណាកស្រុកដោយប្រថុយប្រថាន ជាពិសេសផ្តោតលើស្ត្រី។
២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែបង្កើនទីផ្សារការងារក្នុងស្រុកឲ្យបានច្រើន ផ្តល់ទុន និងបច្ចេកទេស សំរាប់វិស័យកសិកម្ម ជាពិសេសស្វែងរកទីផ្សារសំរាប់កសិផលរបស់ប្រជាពលរដ្ឋ។
៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹងការអនុវត្តច្បាប់ ដាក់ទោសទណ្ឌឲ្យបានធ្ងន់ធ្ងរចំពោះជនជួញដូរមនុស្ស និងវិធានការតឹងរឹងចំពោះក្រុមហ៊ុនជ្រើសរើសពលករ ដែលមិនគោរពគោលការណ៍ច្បាប់ការងារ មានការកេងប្រវ័ញ្ចប្រាក់ខែពលករ និងការកំណត់អាណត្តិការងារ។
៤. ស្ថានទូត និងកុងស៊ុលខ្មែរដែលនៅក្រៅប្រទេស គួរមានទីតាំងច្រើនជាងនេះ ហើយមានបុគ្គលិកប្រចាំការ និងសកម្មនៅតាមការិយាល័យ ដើម្បីឆ្លើយតបបញ្ហា និងជួយដោះស្រាយរាល់ទុក្ខកង្វល់របស់ពលរដ្ឋ និងគួរមានលេខទូរស័ព្ទ Hotline នៅក្រៅប្រទេស ជាពិសេសប្រទេសចិន ដើម្បីអង្គការសង្គមស៊ីវិល និងស្ត្រីរងគ្រោះដែលត្រូវការជំនួយ អាចទាក់ទងឲ្យជួយពួកគាត់បានទាន់ពេលវេលា។

## ប្រជាពលរដ្ឋ៖

១. ប្រជាពលរដ្ឋ មុននឹងសម្រេចចិត្តធ្វើចំណាកស្រុក គួរប្រមូលព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ កុំឆាប់ជឿតាមការអូសទាញរបស់មេខ្យល់ ដោយគ្រាន់តែសន្យាថា ជួយរកការងារទទួលបានប្រាក់ខែច្រើន និងទទួលបានប្តីដែលមានទ្រព្យសម្បត្តិជីវភាពល្អប្រសើរ។
២. ក្នុងករណីសម្រេចចិត្តធ្វើចំណាកស្រុក គួរធ្វើដោយមានឯកសារត្រឹមត្រូវ មានអាសយដ្ឋានលេខទំនាក់ទំនងសម្រាប់ជួយអន្តរាគមន៍ ក្នុងពេលមានបញ្ហាអ្វីមួយកើតឡើង។
៣. សម្រាប់គ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ហើយទទួលរងនូវការរំលោភបំពាន គួរផ្តល់ ព័ត៌មាន ឬស្វែងរកសេវាជំនួយជាបន្ទាន់។
៤. លើកទឹកចិត្ត និងមិនរើសអើងចំពោះសមាជិកគ្រួសារខ្លួនដែលកំពុងមានញ្ហា ដែលជាកត្តាធ្វើឲ្យគាត់អាចនឹងបន្តការចំណាកស្រុកបន្ថែមទៀត។

## ទំនាក់ទំនងយើងខ្ញុំ៖

ផ្ទះលេខ៣ ,ផ្លូវលេខ១៥៨ ឬឧកញ៉ាទ្រឿងកាង, សង្កាត់បឹងរាំង, ខណ្ឌដូនពេញ,រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ៖ 1024

ទូរស័ព្ទលេខ ៖ 023 218653 / 023 210518 / 023 990544

លេខទាន់ហេតុការណ៍៖ 086 792 666 / 097 616 2790

អ៊ីម៉ែល ៖ info@adhoccambodia.org

គេហទំព័រ ៖ www.adhoccambodia.org

ហ្វេសប៊ុក ៖ www.facebook.com/Adhoccam

ធ្វីតធ័រ ៖ www.twitter.com/Adhoccam